# សម្ភាសន៍ជាមួយ ខឹម យាន ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ“ប្រធានកងចល័ត”

## ស្រុកកំណើតនៅភូមិព្រែកតូច ឃុំព្រែកតូច ស្រុកស្អាង ខេត្តកណ្ដាល

## សព្វថ្ងៃរស់ភូមិទួលចារ ឃុំកណ្ដាល ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ

## ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី

## ០១:៤៧ :៥១

## ៥៤ ទំព័រ

បូលីៈ បាទ! អ៊ីចឹងម្ដងទៀត ខ្ញុំសូមអគុណ ពូដែលពូអនុញ្ញាតឲ្យខ្ញុំ សាកសួរអំពីប្រវត្តិខ្លះៗណាពូ ។ ជាដំបូង ខ្ញុំសុំស្គាល់ឈ្មោះពូផង ។

យានៈ បាទ! ខ្ញុំបាទឈ្មោះ ខឹម យាន ។

បូលីៈ សព្វថ្ងៃពូអាយុប៉ុន្មាន?

យានៈ ខ្ញុំអាយុ៥៨ ។ ចូល៥៨ហើយឆ្នាំថ្មី ។

បូលីៈ ហើយពូមានតួនាទីជាអីពូ រាល់ថ្ងៃពូ ។

យានៈ រាល់ថ្ងៃ ខ្ញុំមានតួនាទីជាជំទប់ទី១ ។

បូលីៈ ជំទប់ទី១ ?

យានៈ បាទ!

បូលីៈ ជំទប់ទី១ ឃុំទំនប់ដាច់ ។

យានៈ បាទ!

បូលីៈ ពូមានស្រុកកំណើតនៅឯណាដែរ កើតជា?

យានៈ ស្រុកកំណើតខ្ញុំនៅនែក៎ ស្រុកស្អាង ។

បូលីៈ ស្អាងកោះធំយើង?

យានៈ ស្រុកស្អាង ព្រែកតូច ។

បូលីៈ ស្រុកស្អាង ខេត្តកណ្ដាល?

យានៈ ស្រុកស្អាង ខេត្តកណ្ដាល ។ កោះធំទៅក្រោមទៀត ។

បូលីៈ កោះធំទៅខាងក្រោមទៀត?

យានៈ បាទ! ទៅក្រោមទៀត ទៅចម្ប៉ា, ចម្ការរចមាស(ស្ដាប់ពុំបាន) ។

បូលីៈ ស្អាង ពូដែលពូស្គាល់នេះទេ ស្គាល់តាមួយគាត់ឈ្មោះ កុង សាមណាស់? ដែលពូកុងសាម ទេ?

យានៈ អត់ទេ ។

បូលីៈ ប្រហែលជាពូចេញមកយូរហើយតាមមើល ។

យានៈ នៅនេះ ខ្ញុំមិនដែលបោលទេ ថ្ងៃអាទិត្យ ថ្ងៃសៅ! ថ្ងៃសៅគឺមកពីព្រឹក សម្រាកតែថ្ងៃអាទិត្យ គឺមកពេលព្រឹក ។ ជួនកាលថ្ងៃអាទិត្យ យើងអត់នេះទៀត យើងការងារផ្សេងៗទៀត ។

បូលីៈ បើអញ្ចឹងបន្តមកទៀត សព្វថ្ងៃនេះពូរស់នៅ ភូមិឃុំអីដែរពូ?

យានៈ នៅនេះគឺយើងខ្ញុំនៅភូមិ ទួលចា ។

បូលីៈ ទួលចា?

យានៈ បាទ!

បូលីៈ ឃុំកណ្ដាល?

យានៈ ឃុំកណ្ដាល ។

បូលីៈ ស្រុកត្រពាំងប្រាសាទ ។

យានៈ ស្រុកត្រពាំងប្រាសាទ ។

បូលីៈ ខេត្តឧត្តរមានជ័យ?

យានៈ បាទ!

បូលីៈ កាលដែលពូ នៅពីតូចៗមកហ្នឹង បានចូលស្រុកសាលារៀនអីបានត្រឹមថ្នាក់ទីប៉ុន្មាន ដែលកាលហ្នឹង?

យានៈ ខ្ញុំរៀនពីថ្នាក់ពីសង្គម រៀនថ្នាក់ទី១០ ពីសង្គមណា ។

បូលីៈ បើយើងធៀបមកឥលូវ ទី៣ ទី៤ហ៎ពូ?

យានៈ មិនយ៉ាងម៉េចព្រោះយើង កាលហ្នឹងថ្នាក់ទី១០អត់ទាន់មានអក្សរបារាំងទេណា៎ ។ យើងរៀនតែខ្មែរធម្មតាទេ ។

បូលីៈ នៅសាលាណាពូ?

យានៈ នៅសាលានេះ សាលាយើងក្រាំងយ៉ៅនោះ ។

បូលីៈ បឋមសិក្សាក្រាំងយ៉ៅ?

យានៈ ហ្នឹងហើយ វត្តអង្គារាម ។

បូលីៈ ហើយពូរៀនដល់ថ្នាក់ទី១០ យ៉ាងម៉េចបានជាឈប់ត្រឹមហ្នឹង?

យ៉ានៈ យើងរដ្ឋប្រហារឆ្នាំ៧០ ។ ខ្ញុំទើបតែអាយុវា១៣,១៤ អីចឹងរដ្ឋប្រហារទៅឆ្នាំ៧០ យើងកើតសង្គ្រាម ។ ដល់ឆ្នាំកើតសង្គ្រាម ឆ្នាំ៧៤បានយើង អើធម្មតាថាកើតសង្គ្រាមអីចឹងគេ បើយើងមិនស្ម័គ្រចិត្ត ក៏គេចាប់យើងដែរ ។ អីចឹងហើយក៏!

បូលីៈ គាត់ទៅវិញហើយ ឬក៏នៅចាំងនោះសិន?

យ៉ានៈ អីចឹងរដ្ឋប្រហារយើងឈប់បានរៀនសូត្រហើយស្រុកយើងកើតសង្គ្រាមវឹកវរនោះ គេហៅធៀវ ហៅអីចឹងណា! ហើយខាងខ្ញុំបែកគ្នានៅភូមិហ្នឹងទៀត ឆ្នាំ៧០ហ្នឹង ។

បូលីៈ ពូចូលបដិវត្តន៍ហ្នឹង ចូលឆ្នាំប៉ុន្មានពូ?

យ៉ានៈ ចូល៧៤ ។

បូលីៈ មិនមែន៧០ភ្លាមទេអីចឹង?

យ៉ានៈ អត់ទេ! ៧០វាយើងនៅតូច ។

បូលីៈ ពី៧០ មក៧៤ហ្នឹងមក ស្ថានហ្នឹងស្ថិតនៅក្រោម ការគ្រប់គ្រងលន់ នល់ ឬខ្មែរក្រហមហើយ?

យ៉ានៈ អាហ្នឹងវា ប្រទាញប្រទង់ហើយអូន ។

បូលីៈ ប្រទាញប្រទង់គ្នាទៅមកចេះ?

យ៉ានៈ បាទ! កន្លែងហ្នឹងប្រទាញ ប្រទង់ហើយឆ្នាំ៧០ហ្នឹងណា ។

បូលីៈ បានន័យថាមិនទាន់ស្ថិតនៅក្រោមនរណាច្បាស់លាស់ទេ?

យ៉ានៈ បាទ! អត់ទេ ។

បូលីៈ វាយទៅវាមក?

យ៉ានៈ ហ្នឹងហើយ ។

បូលីៈ ហើយដល់អីចឹង ប្រជាជនគាត់រស់នៅយ៉ាងម៉េចទៅអីចឹង ដល់ពេលវាទៅវាមកអីចឹង?

យ៉ានៈ យើងភៀសទៅ ស្រុកគេស្រុកឯងទៅណាស់ ដល់ស្ងប់ទៅ រត់មកវិញអីចឹងទៅ មកខ្នារ មកភ្នំជីសូរ ផ្ទះបងប្អូន តាមរយៈផ្ទះបងប្អូនណា៎ ប្អូនពូមីងមាខ្ញុំហ្នឹង ។

បូលីៈ មកខាងតាកែវនេះវិញ?

យ៉ានៈ មកនេះវិញ! មកតាកែវ វាយគ្នានៅឯតាកែវទៀត ។

បូលីៈ ដល់តែពេល៧៤ បានពូចូល?

យ៉ានៈ បាទ! បានខ្ញុំចូល ។ នៅកងតំបន់២៤?

បូលីៈ នៅកងតំបន់២៤?

យ៉ានៈ បាទ!

បូលី៖ ភូមិភាគអីគេពូ?

យាន៖ ភូមិភាគយើង! យើងនៅខាងនេះមិនមែនភូមិភាគបូព៌ាទេ យើងនៅភូមិអីទេ នៅតំបន់២៤ ។

បូលី៖ ២៤ វាចូលបូព៌ាហើយ ។

យាន៖ ចឹង?

បូលី៖ បាទ!

យាន៖ បូព៌ាម្ទាង! ម្ទាងទន្ទេ ។

បូលី៖ បូព៌ា២១,២២,២៣,២៤ ។

យាន៖ គេហៅ!

បូលី៖ បើ២៥ គេហៅនិរតី ។

យាន៖ មិនមែនតំបន់នេះទេ ខ្ញុំភ្លេចហើយ ខ្ញុំនៅក្នុងកងតំបន់ ហើយបានដល់ឆ្នាំចូល៧៥ បានខ្ញុំចូលនៅកងពលលេខ១ ។

បូលី៖ កងពលលេខ១នៅភូមិភាគអីគេពូ?

យាន៖ ភូមិភាគអីទេ! ភ្លេចហើយមិនដឹងភូមិភាគអី កងពលលេខ១ ។

បូលី៖ ពីណាគេមេកងលេខ១?

យាន៖ កងពល១១ ។

បូលី៖ ១១ហ៎?

យាន៖ បាទ! ១១ ។

បូលី៖ ពិសេសអីចឹង?

យាន៖ បាទ! កងពល១១, ហ៎ កងពលឈ្មោះស្អីទេ ។

បូលី៖ មេកងពល?

យាន៖ បាទ! ឈ្មោះស្អីទេ យើងមិនដែរឃើញគេទេ ។

បូលី៖ មិនមែនតា០៥យើងទេ?

យាន៖ មិនមែនទេ ។ ខ្ញុំបែកភ្នំពេញ បានខ្ញុំមកចូល១៤នេះ ។

បូលី៖ តា០៥ កងពល១៤?

យាន៖ បាទ! ១៤ កាលមុនគាត់ ដល់ពេលរៀបចំចេញពីភ្នំពេញមកបាន ខ្ញុំនៅវរៈ៨២ ។

បូលី៖ ៨០១?

យាន៖ បាទ! ៨០១យើងនេះ កើតនៅ៨០១វិញ លេខ១៤គេ ហៅ១៤ណ៎ ។

បូលី៖ បាទ!

យានៈ  ខ្ញុំបែកភ្នំពេញបាន៣ខែ មកនៅរតនគិរី ឈរជើងនៅរតនគិរី ។

បូលីៈ  ពេលដែលពូចូលបដិវត្តន៍ ឆ្នាំ៧៤អ្នកណា ជាអ្នកណែនាំពូចូល?

យានៈ  អានេះចេះ! វាទាក់ទង បងប្រុសខ្ញុំ ដល់ឃើញពិបាកធម្មតាចាប់ប្រភាគ់ ប្រភីង បងខ្ញុំ គាត់នៅប្រចាំកងតំបន់ដែរហ្នឹង ក៏យកខ្ញុំទៅ ។

បូលីៈ  អីចឹងបងរបស់ពូជាអ្នកនាំពូចូលទ៌?

យានៈ  បាទ! បងខ្ញុំស្លាប់បាត់ហើយបងបន្ទាប់ខ្ញុំហ្នឹងណា៌?

បូលីៈ  គាត់ស្លាប់ដោយសារអី?

យានៈ  ស្លាប់នៅសម័យ៣ឆ្នាំ ។

បូលីៈ  គេវាយចោល ឬក៏សង្គ្រាម?

យានៈ  អត់សង្គ្រាមទេ ។ ខ្មែរ គេថាយើងខ្មែរ មេកងពលក្បត់អីចឹងណា ព្រោះកាលហ្នឹងយើងធម្មតា តាយុវកកហើយ បេក្ខជនណា៌ ។

បូលីៈ  គាត់នៅក្នុងកងពកណា?

យានៈ  នៅ៨០១ដូចគ្នា ប៉ុនគ្រាន់តែកងពលធំដូចគ្នា ។ បាទ! ខ្ញុំទៅជួបបងម្តង ។ គាត់ឈឺទៅដេកនៅឯថៃ ។ ខ្ញុំទៅធ្វើការភូមិតង ហ្នឹងក៏ជួបបងជិះកង មើលបងសឹងតែមិនស្គាល់ទេ ព្រោះបងខ្ញុំខ្មៅ ស្មៀកដូចខ្ញុំដែរ ដល់សួរទៅ គាត់កាំភ្លើងធំ ។ ធម្មតាតាមរយៈហ្នឹង កងខ្ញុំ មេកងខ្ញុំអីហ្នឹង រៀនអីចឹងជួបស្គាល់ ហើយខ្ញុំតែងតែប្រាប់ថា ទៅជួបបងខ្ញុំអីចេះៗ ។ ដល់ចូល៧៨បាត់ខ្លួន ។

បូលីៈ  ពូដឹងថាបាត់ទៅណាទេ?

យានៈ  បាត់! គ្រាន់តែដឹងថា បងៗគាត់ទៅរៀននោះ គាត់ថា បាត់ៗហើយ អូនដឹងហើយ! ថាអីចឹងណា គេចាប់តាមរយៈខ្មែរ ។

បូលីៈ  តំណែង គាត់ជាអីពេលហ្នឹង?

យានៈ  គាត់! កាលវាបែកភ្នំពេញនេះ គាត់អនុសេនាធំ ដល់ពេលគេរៀបចេញបំបែកពីអគ្គភាពមកនៅកងពល៨០១វិញ មកអនុសេនាតូច ។

បូលីៈ  ធ្លាក់វិញអីចឹង?

យានៈ  ធ្លាក់ ។

បូលីៈ  អត់មានឡើង ធ្លាក់វិញ?

យានៈ  ធ្លាក់ ។ ចុះយើងចេញមកពីកងពល១១ មកឡើងនេះ យើងម៉េចបានឡើង ។

បូលីៈ  ដោយសារតែគាត់ ស្ថិតក្នុងកងពល១១?

យាន៖ បាទ!

បូលី៖ បើយើងនៅក្នុងកងពល១៨ អាចឡើងធំ?

យាន៖ ហ្នឹងហើយ ។

បូលី៖ យល់ ។ ហើយគេចោទថាខ្សែពីណា?

យាន៖ ខ្សែ! តាមរយៈមេដែលអ្នក ដូចថាអ្នកបំពាក់ឲ្យណា មិនដឹងថាវរសេនាធំ ខ្ញុំអត់ស្គាល់ទេ ។

បូលី៖ ពេលដែលគាត់បាត់ខ្លួនហ្នឹង ពូមានបានដឹងទេ ថាក្រោយមកស្លាប់ដោយសារ គេចាប់គាត់ទៅ ដាក់នៅកន្លែងណា មានដឹងទេពូ?

យាន៖ ដឹង! ដឹងតែគេទៅចាប់ ដាក់នៅបានលុង ។

បូលី៖ នៅបានលុង?

យាន៖ បាទ!

បូលី៖ នៅមន្ទីរសន្តិសុខគេហ្នឹង ឈ្មោះអីគេហ្នឹង?

យាន៖ អត់ស្គាល់ឈ្មោះអី ។

បូលី៖ ពូដែលឮមន្ទីរសន្តិសុខបឹងកន្សែងទេ?

យាន៖ ហ្នឹងហើយ គេថាបានលុងបឹងកន្សែងហ្នឹង ប៉ុន្តែខ្ញុំមិនដឹងថាឈ្មោះអី ឈ្មោះអីទេណា ។

បូលី៖ ពីណាគេប្រធានមន្ទីរ?

យាន៖ អត់ស្គាល់ទេ ។ ខ្ញុំម៉េចស្គាល់ ឆ្ងាយណាស់ ឃ្លាតឆ្ងាយណាស់ ។

បូលី៖ ពូនៅ៨២ណ៎ ។

យាន៖ បាទ! ខ្ញុំនៅវរ៨២នេះ ។

បូលី៖ នៅខាង!

យាន៖ ខ្ញុំនៅនេះម្តុំសៀមប៉ាងនេះ ។

បូលី៖ សៀមប៉ាងវិញ ស្ទឹងត្រែង?

យាន៖ ហ្នឹងហើយ ឈរនៅសៀមប៉ាងវិញ ។

បូលី៖ អីចឹង! បានន័យថាឆ្ងាយពីបានលុង ។

យាន៖ បាទ! ឆ្ងាយណាស់មិនដែលស្គាល់ទេខ្ញុំនោះ បើវីនសៃស្គាល់ ។

បូលី៖ ដើរទៅដល់វីនសៃដែរហ៎?

យាន៖ បាទ! ខ្ញុំទៅវីនសៃ ។

បូលី៖ ពូស្គាល់ ពូឆោមសែ?

យាន៖ អត់ទេ!

បូលី៖ ពូសែ ខ្ទាក់ភ្នែក១ចំហៀងណា ។ គាត់នៅអន្លង់វែងនេះ ប្រពន្ធគាត់នៅឈ្មោះមីងភាពណា ភាពដែលទើបស្លាប់ថ្មីៗនេះ ។

យានៈ ភាពក្រុមប្រឹក្សាឃុំហ្នឹង?

បូលី៖ បាទៗ! ត្រូវទេ ។

យានៈ ប៉ុនពីដើមគាត់នៅឯណា ខ្ញុំអត់ដឹងទេ! ទើបមកស្គាល់គាត់គ្នា ខ្ញុំនៅនេះណាអូនណា ។ កាល៩១ មកចុះនៅនេះ បានខ្ញុំស្គាល់ ។

បូលី៖ អូរគាត់មកហ្នឹងដែរ?

យានៈ បាទ! គាត់មកនៅនេះដែរ ។ គាត់មកមន្ទីរតា០៥នេះ ទឹកដីមន្ទីរផ្ទះគាត់ ។

បូលី៖ ផ្ទះតា០៥?

យានៈ បាទ! ហើយជុំវិញនេះសុទ្ធតែកន្លែងមន្ទីរគាត់ ។

បូលី៖ គាត់ស្និតជាមួយតា០៥?

យានៈ បាទ!ហ្នឹងហើយ គាត់នៅមន្ទីរ ។

បូលី៖ នៅមន្ទីររបស់តា០៥?

យានៈ បាទ!

បូលី៖ ប៉ុនពូអត់ដឹងថាមូលហេតុអីបានបងប្រុសពូស្លាប់ទេណ៎?

យានៈ មិនថាកាលបែក៧៩ ដែលបែកហើយអ្នកឃើញគេមកក៏មកទៅណា អ្នកទោសអីចេញមានរត់រួចណា តែបងខ្ញុំបាត់ឈឹង អត់មានដំណឹង ។

បូលី៖ រហូតដល់ឥលូវហ្នឹង?

យានៈ បាទ! ទាល់តែសព្វថ្ងៃ ។

បូលី៖ ពូនៅវរសេនាធំលេខ៨២ ខាងសៀមប៉ាំងហ្នឹង នៅធ្វើអីនៅម្តុំហ្នឹង?

យានៈ មានធ្វើអី មានតែធ្វើស្រែអូន ។

បូលី៖ កងទ័ពហ្នឹង?

យានៈ បាទ! មួយវរសេនាតូចខ្ញុំហ្នឹង គឺ៣៥០ហិចតា ហើយដល់អីចឹងខ្ញុំ ខ្ញុំអត់ដែលបានទេវាយយួនទេ ក្រោយមកក៏គេបកវរសេនាធំក៏ចាត់តាំងឲ្យខ្ញុំទៅគ្រប់គ្រងកុមារភូមិភាគ ខ្ញុំត្រូវមើលកុមារ ១០០នាក់ ។

បូលី៖ កុមារភូមិភាគ?

យានៈ បាទ! កុមារជនជាតិយើងណា ។ ព្នង គួយ ចារ៉ាយ គ្រឹង កាវែតអីហ្នឹង ខ្ញុំទៅគ្រប់គ្រងមើលកុមារ រហូតដល់យួនវាយចូល ។

បូលីៈ មើលរបៀបម៉េច?

យានៈ យើងទៅថៃទាំងកុមារបង្រៀនអក្សរសាស្ត្រយើងហ្នឹងតាំងពីយើងបង្រៀនអក្សរសាសន៍យើងហ្នឹង ហើយគ្រប់គ្រងមើលការពារកុមារហ្នឹងគេឲ្យទៅមើល ទៅមើលអីចឹង ខ្ញុំពីរនាក់ៗ បែកម្នាក់បងៗខ្ញុំឈ្មោះបងជន់ៗអ្នកបង្រៀនអក្សរ ម៉ែខ្ញុំនៅបង្រៀនធ្វើចុងភៅបាយស្ល ព្រោះអីកុមារវាទម្លាប់ធ្វើតាមឪពុកម្តាយវាស្លអាដំឡូង ស្លឹកដំឡូងមីយើងហ្នឹង វាបុកឲ្យម៉្ដ។ យើងអត់បេះហូបទេ សម្លខាប់គេ ហើយយើងស្លឆាម្ជូរគ្រឿងអីចឹង យើងមានៗ របៀបយើងហូបខ្មែរ ។

បូលីៈ ម៉េចក៏មិនឲ្យកុមារទាំងអស់ទៅនៅជាមួយម៉ែឪគេទៅ?

យានៈ អត់! គេខាងហ្នឹង គេប្រមូលផ្ដុំកុមារសម័យនោះ ។

បូលីៈ ហេតុផលអី?

យានៈ ដឹង! ខ្ញុំមិនដឹងដែរ ។ កុមារភូមិភាគៗហ្នឹង កុមារ១ភូមិភាគដែរ ។ ដល់អីចឹង ខ្ញុំទៅមើលកុមារហ្នឹងឯង មិនដឹងជាហេតុផលអីអត់ដឹងទេ ប៉ុនកុមារនោះសុទ្ធតែអាយុខ្លះ១០ឆ្នាំ, ខ្លះ១៥ មួយៗ ផ្ដេកភ្លក់ហ្នឹងឯង ។ ជិតព្រំដែនលាវ ខ្ញុំទៅមើល គេហៅណាំផុង, ណាំភាំ ខ្ញុំទៅមើលហ្នឹង ។ កន្លែងមន្ទីរគេហ្នឹង ។

បូលីៈ ឈ្មោះជាលាវតែម្ដង?

យានៈ ឈ្មោះជាលាវតែម្ដង ឈ្មោះ ណាំផុង ណាំភាំតែម្ដង ប៉ុនដីខ្មែរយើងទេណា ។

បូលីៈ ប្រែមកថាម៉េចខ្មែរយើង?

យានៈ មិនដឹងថាម៉េច ។

បូលីៈ ណាំផុង ណាំភាំ ។

យានៈ ណាំផុង ណាំភាំ អីចឹងឯង ។

បូលីៈ កុមារទាំងអស់មាននាទីធ្វើអី?

យានៈ អត់មានធ្វើអីផង! បានអង្គុយតែដាំអំពៅដាំអញ្ចឹងទៅណា ។ ខ្ញុំទៅឃើញ មានដាំអំពៅ ដាំអី ប៉ុន្តែអត់ឃើញមានធ្វើអីទេ ។ ហើយក៏មិនឃើញអ្នកខាងណាមកទំនាក់ទំនង ឬខបត្តម្កអី ស្រូវអង្ករអី ព្រោះអីខ្ញុំអត់នៅ១រយៈតូច យួនវាយចូលមក ។ ខ្ញុំក៏នាំរត់ចូលមក មកហ្នឹង ខ្ញុំរត់ឆ្លងទន្លេមេគង្គ ណាក៏ឃើញម៉ែឪគេវិញ គេទៅណា ដំណាលគ្នា អត់ជួបម៉ែឪក៏មកបេះមក រហូតដល់ខ្ញុំត្រលប់ទៅវិញ រត់ទៅលក៏ត្រលប់មកដល់ត្រឹមគេហៅដងផ្ចិតនេះ ខ្ញុំត្រលប់ទៅវិញ មិនមែនដងផ្ចិតទេ មកដល់នេះ រត់មក មកដល់យើងចំរើនផល បាទ! នៅព្រះវិហារនេះ បានបកទៅវិញ ។ បកទៅវិញ ទៅនៅជាមួយប្រជាជនយើងនៅកោះញ៉ែ បាទអាហ្នឹងបែកគ្នាហើយ ។

បូលីៈ ខ្ញុំសុំសួរកន្លែងកុមារហ្នឹងតិច ។ ពេលដែលកុមារមើលការខុសត្រូវហ្នឹង ឪពុកម្តាយមានមក លេងកុមារហ្នឹងដែរទេ?

យានៈ អត់គាមទេអូន ។

បូលីៈ កុមារមានទៅលេខម៉ែឪគេទេ?

យានៈ អត់ទេ! តែខ្ញុំមិនដឹងថាច្បាប់គេយ៉ាងម៉េច អត់មានទេ ។

បូលីៈ ទទួលបញ្ជាពីណាមកឲ្យមកមើលកុមារនេះ?

យានៈ នេះខ្ញុំទទួលពីវរសេនាធំ ។

បូលីៈ ឈ្មោះអី?

យានៈ កោលនោះគាត់គ្រប់គ្រង មិនមែនវរសេនាធំទេ វរសេនាតូច ស្លាប់បាត់ហើយ ។ គាត់ស្លាប់ បាត់ហើយ ។

បូលីៈ អីចឹងពូនៅ៨២ សៀមប៉ាងហ្នឹង ក្នុងតួនាទីជាទាហាន ប៉ុន្តែធ្វើស្រែ?

យានៈ បាទ! ធ្វើស្រែហ្នឹងអូន ។

បូលីៈ បន្ទាប់មកគេឲ្យមើលកុមារ ។

យានៈ បាទ! មើលកុមារ ។

បូលីៈ បន្ទាប់ពីមើលកុមារហើយ យួនវាយចូល ឆ្នាំចុង៧៨ ដើម៧៩?

យានៈ បាទ! ដើម៧៩ហ្នឹង ។

បូលីៈ ពេលដែលយួនវាយចូលហ្នឹង ពេលហ្នឹងពូកំពុងធ្វើអី ខ្ញុំចង់ដឹងពីសកម្មភាព ពេលដែលពូ ដែលកំពុងច្បាំងគ្នាមកនោះ ។

យានៈ នៅច្បាំងនោះ ខ្ញុំនៅមើលកុមារច្រូតស្រូវនៅសៀមប៉ាងហ្នឹងឯង ។

បូលីៈ កុមារច្រូតស្រូវ?

យានៈ បាទ! ខ្ញុំគ្រប់គ្រងជាមួយចល័តទៀត ។ គេឲ្យខ្ញុំមើលចល័តណា ចល័តដែលយើងទៅច្រូត ។ ចុះទ័ពទៅមុខអស់ហើយ នៅតែខ្ញុំមួយកុមារហ្នឹង នៅចល័តនៅ ខ្ញុំមើលគ្រប់គ្រងចល័តផង ។

បូលីៈ ចល័តតំបន់ ឬក៏ចល័តភូមិភាគ?

យានៈ មិនដឹងចល័តមកពីណានោះ អូរចល័ត អូរនោះង ២០០ ទៅ៣០០ច្រើនដែរ ។

បូលីៈ ចល័តមកពីណា?

យានៈ ២០០ ទៅ៣០០ ។

បូលីៈ ច្រើនដែរ?

យានៈ បាទ! ច្រើនដែរ ។ ស្រូវខ្ញុំប្រហែលជា៣៥០ហិចតាអូនណាំ ហើយសុទ្ធតែស្រូវស្ទូង មិនមែនស្រូវពង្រោះទេ ។ ជង្រុកបណ្តោយ ទទឹងជាង២៥ បណ្តោយ៥០ គ្រាន់តែជង្រុកហើយ១០បន្ទប់នោះ ។ ឆេះគ្រាន់តែឆេះមួយចំហៀងមួយវរសេនាធំស៊ីអង្ករឆេះ៣ខែបានអស់ គ្រាន់តែអង្ករឆេះ ខ្លោចៗ ឲ្យស៊ីអស់ស្រូវហ្នឹង បានគេឲ្យស៊ីស្រូវថ្មី ។

បូលី: ម៉េចបានឆេះ?

យានៈ គេដាក់ម៉ាស៊ីនក្បែរណាអូនណា គេធ្វើព្រះវិហារហូរដាក់ហ្នឹងនេះវាតែម្តង អាថាសកិនតែម្តង គេធ្វើសន្ទុះបិទបើក ដល់ទៅមិនដឹងយ៉ាងម៉េចឆេះ ។

បូលី: អីចឹងសម្បូរស្រូវណាំពួណាំ?

យានៈ ស្រូវពួកខ្ញុំ និយាយរួមដឹក ផ្តល់ឲ្យកងពល ។

បូលី: យកស្រូវហ្នឹង ទៅឲ្យកងពល?

យានៈ បាទ! កងពលមកដឹកម្តង៣០ ទៅ៤០ឡាននោះ ។

បូលី: នៅវីនសៃនេះ?

យានៈ បាទ! ដឹកទៅវីនសៃ ។

បូលី: ម្តង៤០ឡាន ?

យានៈ បាទ!

បូលី: ហើយគេយកទៅណាទៀត?

យានៈ មិនដឹងទេ! ដឹងតែឡានចូលទៅដឹក នៅសៀមប៉ាង ។

បូលី: យើងដឹងតែដឹកឲ្យគេទៅណាំ?

យានៈ បាទ! ឡានគេមកដឹកយក ។

បូលី: តែមិនដឹងថាគេយកទៅណាទេ?

យានៈ មិនដឹងទៅណាទេ ហ៊ូប្រវត្តិខ្ញុំជួរចត់ណាស់ ។

បូលី: ខ្ញុំចង់ដឹងនៅពេលដែលវៀតណាវាយចូលមកពូ ពូរត់យ៉ាងម៉េច ដឹកនាំកម្លាំងកុមាររត់យ៉ាងម៉េច?

យានៈ រត់ដើរកាត់ព្រៃអត់មានអត់មានជិះអីទេ ។ តាមប្រជាជនយើងចឹងណា ដើរកាត់ពីសៀមប៉ាងមក មកចំ បុកមកកោះញ៉ែកនែក ។ មកគេហៅស្អីគេខាង ស្អីបេះ ដឹងតែឆ្លងមុំខាងកោះញ៉ែមកព្រះនង្គ័ល ។

បូលី: មកព្រះនង្គ័ល?

យានៈ បាទ! ឆ្លងមកចំកោះញ៉ែចឹងមក មកព្រះនង្គ័ល ។

បូលីៈ មកព្រះនគ្គ័លនៅខាងថាឡាបរិវ៉ាត់អីយ៉ាងម៉េចទៅ?

យានៈ បាទ! ថាឡាបរិវ៉ាត់ ផែប កំពង់ស្រឡៅហ្នឹង ។

បូលីៈ ពូឆ្លងទន្លេចឹង?

យានៈ បាទ!

បូលីៈ បានអីឆ្លង?

យានៈ កាលនោះវាទូក ។

បូលីៈ ទូកប៉ុណ្ណា?

យានៈ ទូកប្រជាជន ជិះ៨ ទៅ១០នាក់ ។

បូលីៈ ចែវទូកឆ្លងខ្លួនឯងតែម្តងអីចឹង?

យានៈ ចែវខ្លួនឯង ។

បូលីៈ ពេលដែលពូឆ្លងហ្នឹងប៉ុន្មាននាក់ទាំងអស់?

យានៈ ឆ្លង! ឧបមាថាខ្ញុំនៅ៣៥នាក់ទេ គេទៅតាមម៉ែឪគេអស់ នៅសល់តែប៉ុណ្ណឹង ។

បូលីៈ សល់ប៉ុន្មានពូអ្នកចម្លងទៅ?

យានៈ បាទ! ខ្ញុំអ្នកចម្លងមក ។

បូលីៈ ពេលដែលកំពុងតែឆ្លងនឹងមកយួនមានដេញបាញ់ទេពេលហ្នឹង?

យានៈ អត់ទេ! អត់ទាន់ដឹងអីទេ ។ យួនអត់ទាន់មកដល់ទេ ដល់ខ្ញុំបកមកវិញបាន ចូលមកដល់កោះញ៉ោ បានយួនចូល ។

បូលីៈ កោះញ៉ោ នៅក្នុងទឹកដីខេត្តណា?

យានៈ ទឹកដី មិនដឹងខេត្តណា មិនស្រួលនៅនឹងស្ទឹងត្រែងមិនដឹង ។

បូលីៈ ពូឆ្លងពីសៀមប៉ាង មកថាឡាបរិវ៉ាត់?

យានៈ បាទ!

បូលីៈ ឆ្លងទន្លេនឹង ឆ្លងម្តុំណា ក្បែរព្រំដែនលាវទេ?

យានៈ ព្រំដែនលាវ កោះញ៉ោហ្នឹងហើយចំព្រំដែនហើយខ្ញុំ ។

បូលីៈ ឬក៏ក្នុងទឹកដីលាវ?

យានៈ អត់ទេ! ដីខ្មែរយើង ។

បូលីៈ ហើយទឹកហូរខ្លាំងទេកាលហ្នឹង?

យានៈ អត់! ខែប្រាំងមានហូរទេ ។

បូលីៈ ខែ១?

យាន៖ បាទៗ!

បូលី៖ ខែ១ ដូចម៉ុមុនហ្នឹងបន្តិច ក្រោយហ្នឹងតិច?

យាន៖ បាទ!

បូលី៖ ឥលូវយើង ពាក់កណ្ដាលខែ១២?

យាន៖ បាទ!

បូលី៖ អត់ច្រើនទេ ទឹកវាងស្រកហើយ ។

យាន៖ ហើយទឹកម៉ុហនឹងវាងបែកផង ហើយទឹកអត់ហូរខ្លាំងទេ ព្រោះអីវាមានកោះម្នោះហើយទឹកវាបែកធំ ។ យើងជិះមកកោះ ហែលមកកោះ ឆ្លងមកកោះ ។

បូលី៖ ឆ្លងមក មកខាងព្រះនគ្គ័ល?

យាន៖ ព្រះនគ្គ័ល ។

បូលី៖ ចេញពីព្រះនគ្គ័លមក ពេលដែលយើង ឡើងពីទន្លេមកពេលហ្នឹងមាននរណាមកទទួលយើងឬទេ?

យាន៖ អត់ទេ! យើងដើរជាមួយទាំងកងទ័ព មីងគ្រូសារកងទ័ពអីចឹងណាយើងទៅ ។ ដើរទាំងអស់អត់មាននរណាមកទទួលទេ យើងទៅសម្រាកហើយអត់មានប្រជាជនទេ ប្រជាជនរត់អស់ហើយ ។ យើងទៅដេកតែហ្នឹងវត្តព្រះនគ្គ័លហើយទៅដេកនៅហ្នឹង ។

បូលី៖ បានន័យថាអ្នកដែលរត់ទៅហ្នឹងសុទ្ធតែជាកងទ័ព និងគ្រួសារកងទ័ព?

យាន៖ បាទ!

បូលី៖ ហើយនឹងកងចល័តកុមារ ។

យាន៖ កងអីហើយហ្នឹង ។

បូលី៖ ប្រជាជនរត់ទៅណាអស់ហើយទៅ ។

យាន៖ មិនដឹងប្រជាជនទៅណា ខ្ញុំអត់ឃើញ អត់ជួបមិនដឹងគាត់ទៅណា ទាល់តែយើងមកវិញបានជួបគាត់ ។ ខ្ញុំបកមកវិញណា ខ្ញុំលាក់កាំភ្លើងលាក់ចោលអស់ហើយ ។

បូលី៖ លាក់យ៉ាងម៉េច?

យាន៖ បានន័យថាយើងលាក់ ដាក់ចោលក្នុងបំពង់ស្រឡៅ និងដើមស្រឡៅធំៗណា ។ គ្រាប់បែក គ្រាប់អី លាក់ទៅព្រោះយើងចូលទៅនៅជាមួយប្រជាជនដែរណ៎ា ។ បាទ! យើងសុំប្រជាជននៅតាមផ្ទះអីចឹងទៅ ។

បូលី៖ ពេលដែលពូឆ្លងទន្លេហើយ ឡើងដល់ច្រាំងទន្លេហើយ ពេលហ្នឹងថាពូដឹកនាំកុមារដើរតាមកងទ័ពអីចឹងទៅ?

យាន៖ បាទ! ដើរមកកាត់ ដូចខ្ញុំថាអីចឹងដើរមកកាត់ជង្គឹត ។

បូលី៖ មកដល់!

យាន៖ មកដល់ជង្គឹតយើងនេះ ព្រះវិហារនេះដែរ ។

បូលី៖ ស្រុកអីគេ?

យាន៖ អាហ្នឹង ស្រុកឆែប ។

បូលី៖ ស្រុកឆែបហ៎?

យាន៖ បាទ!

បូលី៖ ជង្គឹតហ្នឹងជាអី ជាឃុំ ឬជាភូមិ?

យាន៖ អាចជាភូមិ មិនជាភូមិ ឬក៏ជាឃុំ ជង្គឹតហ្នឹង ព្រោះអីភូមិទៅដាច់ព្រសយាលហ្នឹងណា មានតែជង្គឹតហ្នឹងមួយ ដែលខ្ញុំដើរកាត់ ពីហ្នឹងមកបានដល់ចេញពីជង្គឹតហ្នឹងទៀតបានទៅដល់ម្លូព្រៃ ។ ចេញពីម្លូព្រៃបានមកដល់ស្ទឹងសែន បានមកចម្រើនផល ។ មកទើបចម្រើនផលហ្នឹង បានមានប្រជាជនចម្រើនផលហ្នឹងណា ។ ដល់ប្រជាជនឲ្យត្បាល់កិន ឲ្យស្រូវឲ្យអី ខ្ញុំនៅហ្នឹង ដល់មិនដឹងជាទៅណាទៀត ដើរបេះតែគេដែលណា មេខ្យល់គេបេះតែនាំទៅ ។ គេថាអ៊ូទៅមិនរួចទេបកទៅវិញក៏បកមកវិញ បកមកក្រោយវិញសារដានវិញ ។

បូលី៖ ទាំងកុមារទាំងអី?

យាន៖ បាទ!

បូលី៖ បកមកណាវិញ?

យាន៖ ដូចខ្ញុំថាអីចឹង បកមកព្រះនគ្គលវិញ ប៉ុន្តែមួយជំនាន់នោះ យើងដូចខ្ញុំថាអីចឹងចោលអស់ហើយ កាំភ្លើងលែងមានហើយ តែខ្លួនទទេអីចឹងខោអាវយើងយោធាក៏យើងចោលដែរ ។ យើងរកអាវស៊ីវិលពាក់អីចឹងទៅ ហើយខ្ញុំសុំប្រជាជននៅតាមផ្ទះ បានចាប់ផ្ដើមកង់ទ័ពវៀតណាមចុះមកពីលាវ ។ (ស្ដាប់ពុំបាន) ដាច់ជាកង់ៗ យើងភ័យណា ។

បូលី៖ ធ្វើអី?

យាន៖ ចុះយើងជួយប្រជាជននៅផ្ទះគាត់ ដូចរាប់អានម៉ែធម៌ឪធម៌ចឹងទៅណា ខ្ញុំចាប់ក្របីចាប់អីឲ្យគាត់ជំនាន់នោះ ខ្ញុំដឹកស្រូវយកស្រូវកន្លែងឃ្លាំងសហករណ៍ហ្នឹងនោះ ដាក់លើខ្នងក្របីដាក់ជាមួយគាត់អីចឹងទៅ យកមកទុកដាក់សម្រាប់ធ្វើស្បៀងនោះ ដល់ហើយគាត់យួនចូលមក ភ័យយើងមិនដែលឃើញនោះញ៉ែរ ។ ភ័យម៉្លេះតាំងចិត្តមើល កុំខ្លាចមនុស្សដូចគ្នាតា ម៉ែខ្ញុំលាវហ្នឹងណា៎ ម៉ែធម៌ខ្ញុំលាវ និយាយខ្មែរ ។

បូលី៖ លាវខ្មែរតា?

យានៈ បាទ! លាវខ្មែរ ។ ដល់អីញ្ចឹង ខ្ញុំដូចអន់ភ័យ ។ វាមក វាគ្រាន់តែសួរសុខទុកអីចឹងហើយ វាដើរហួសទៅ ដល់តែយើងដឹងទៅធម្មតា ។

បូលីៈ ម៉េចបានយើងភ័យ?

យានៈ យើងឃើញមុនដំបូងភ័យតែម្ដង ញ័រតែម្ដងចេញ ដូចថាអារម្មណ៍របស់យើងមិនតាំងចិត្តទេ ប៉ុន្តែវាចេញមកពីក្នុងពោះតែម្ដង ដូចថាយើងវាយគ្នាមិនទាន់ដាច់ចេញគ្រាប់ចឹងណាអូន ។ អា មិនទាន់ចេញគ្រាប់ហើយដែលយើងភ័យ ញាក់ពីក្នុងពោះតែម្ដង ទាល់តែបានក្ដាំហើយ ដូចបាត់ អស់ពីក្នុងខ្លួនហើយចឹងណា ។

បូលីៈ ភ័យខ្លាចយួនបាញ់ចោល ឬយ៉ាងម៉េច?

យានៈ ហ៎ អានេះពាក្យគេថាគេមកវះដាក់ញាត់ស្មៅ ញាត់អីចឹងទៅណា យើងភ័យមកពីយួនដឹងថា ចេះថាតែខ្មែរក្រហម ប៉ុល ពត ៗចឹងទៅណា ។ ចេះតែចង្អុលកាណុងកាំភ្លើងយើង ប៉ុល ពត ៗ គាត់និយាយឡាវអីចឹងទៅណា ។ សុទ្ធតែពួកចេះលាវ បើថាកូនចៅខ្ញុំនេះមិនចេះទេ ។

បូលីៈ យួនហ្នឹងចេះលាវដែរ?

យានៈ ចេះ! មកពីលាវ ។

បូលីៈ យួនសួរថាម៉េចខ្លះទៅពូ?

យានៈ ហ៎វាគ្មានសួរថាម៉េចទេ សួរគ្រាន់តែថាប៉ុល ពត ៗ ឲ្យតែឃើញ ប៉ុល ពត ចឹងទៅណាឲ្យតែ ឃើញប្រុស ៗ ណា ។

បូលីៈ ចេះតែប៉ុល ពតហើយទៅណ៎?

យានៈ បាទ! ប៉ុល ពតចឹងទៅ ។

បូលីៈ ហើយពូនៅជាមួយប្រជាជនហ្នឹងនៅក្នុងភូមិអី ព្រះនន្ទ័ល?

យានៈ ភូមិកោះញ្ញោហ៎ ។

បូលីៈ ភូមិកោះញ្ញោ?

យានៈ បាទ!

បូលីៈ គ្រាន់តែឈ្មោះកោះទេ តែមិនកោះទេហ៎?

យានៈ កោះញ្ញោតែម្ដង! កណ្ដាលទន្លេតែម្ដង ។ កោះញ្ញោ ខាងក្រោមបានមានកោះហាប់ កោះអីណា ក្រោមកោះញ្ញោហ្នឹងណា ។

បូលីៈ បាទ! នៅលើកោះតែម្ដងចឹង?

យានៈ នៅលើកោះ ហើយនៅលើកោះហ្នឹង ។

បូលីៈ ប្រជាជនហើយហ្នឹងកម្លាំងខាងកងទ័ពគ្រួសារខ្មែរក្រហម នេះមួយណាច្រើនជាងមួយណាតាមពូមើល?

យានៈ ពួកខ្ញុំច្រើនជាង ប្រជាជនគាត់មិនទាន់មកអស់ទេប្រជាជនណា៎ ។ កូនគាត់អី បាត់កូនគាត់មិនទាន់មកដល់ជុំគ្នាទេ អីចឹងពួកខ្ញុំច្រើន និយាយរួមជាង១០០នាក់ដែរត្រលប់មកវិញណា ។ ជាង១០០នាក់ ហើយបំបែកនៅតាមផ្ទះៗ ។

បូលីៈ ពួកគាត់មានប្រហែលជាប៉ុន្មានគ្រួសារ?

យានៈ ខ្ញុំមិនដឹងទេ! អត់បានដើរផុតកន្ទុយកោះផង មិនដឹងប៉ុន្មាន ។

បូលីៈ ហើយយួនមកវាសួរ!

យានៈ ប៉ុល ពតៗ ហើយមកគេរៀបចំបាន៤ ទៅ៥ថ្ងៃគេប្រជុំរៀបចំ កាលនោះគេរៀបចំស្អីទេ ខ្ញុំភ្លេចបាត់ហើយ គេថាធ្វើម៉េចកុំឲ្យចំ ប៉ុល ពត អីចឹងទៅណា គេរៀបចំ(ស្តាប់ពុំបាន) ។

បូលីៈ អ៊ូខាងយួនគេប្រជុំ?

យានៈ គេប្រជុំរៀបចំភូមិ រៀបចំអីចឹងណា៎ បានមេភូមិមេអីចឹងណា ។ ប៉ុនអត់មាននរណាដើររណោបវា វារៀបចំហើយ ខ្ញុំឃើញអីចឹង ប៉ុន្តែគាត់ក៏ទុករក្សាសុខឲ្យពួកខ្ញុំដែរ អត់មានមាត់កអីទេណា ។ អត់មានថាអានេះខ្មែរក្រហម អានោះស្អីទេ ។ បាទ! គេជួយលាក់ដែរ ។

បូលីៈ ពូនៅលើកោះញ្ញោប្រហែលជារយៈពេលប៉ុន្មានដែរ?

យានៈ ខ្ញុំនៅបានរយៈពេលជាង១ខែ ។

បូលីៈ បន្ទាប់មកយ៉ាងម៉េចទៀត?

យានៈ ដល់ជាង១ខែបានកម្លាំងយើង កម្លាំងខ្មែរក្រហមហ្នឹងដែលគេរត់ចូលព្រៃណាអូនណា៎ ។ ខ្ញុំទៅអុំទូកដើរដាក់មងនោះ ស្រាប់ជួបពួកយើងហ្នឹងឯងតាមមាត់ច្រាំង ។ ហើយសុទ្ធតែអង្គភាពដែលធ្លាប់ស្គាល់ ។

បូលីៈ យ៉ាងម៉េចទៅ?

យានៈ មកក៏ថាគេកំពុងដើរទៅរកប្រពន្ធកូនគេ ។ ដល់ចឹង ខ្ញុំប្រាប់ថាប្រពន្ធបងឯងនៅនេះៗ ចឹងទៅណា ដល់អីចឹងទៅទាក់ទងគ្នា បានចេះខ្ញុំមកអុំទូកមក មកដាក់មងដាក់អីចឹងទៅជួប ជួបទៅសន្មត់ថ្ងៃគ្នាគេមកយក ។

បូលីៈ ណាត់ថ្ងៃតែម្តង?

យានៈ បាទ!

បូលីៈ គេប្រាប់ថាថ្ងៃណាគេមកយក?

យានៈ ថ្ងៃប៉ុណ្ណេះៗ គេមកយកជួបគ្នានៅនេះៗចឹងទៅណា ។ កាលនេះអត់មាននេះទេ ពួកនោះអត់ទេ អស់ហើយ វាទៅផុតអស់ហើយ យួនណាអូន ។ ធ្លាប់តែនៅអណ្តូងឃ្លាំងដូចខ្ញុំថាអីចឹង គេហៅស្អីខ្ញុំភ្លេចបាត់ហើយ អាហ្នឹងភូមិហ្នឹង កន្លែងឃ្លាំង សហករណ៍ណា ។ ដល់អីចឹងម្តាយធម៌ខ្ញុំអត់ឲ្យមកទេ តែខ្ញុំដូចកម្មពារមិនអស់នៅក្នុងព្រៃ ដឹង យ៉ាងម៉េច គេទៅអស់ហើយ ឲ្យខ្ញុំនៅតែឯង ។ ខ្ញុំទៅបើថាលំបាកយ៉ាងម៉េច ខ្ញុំមករកម៉ែខ្ញុំវិញ ក៏មកដើរកាត់ទាំងយប់ ចេញម៉ោង៧យើងចេញ ។

យានៈ ៧យប់?

បូលីៈ បាទ!

យានៈ ទាំងកុមារទាំងអីចេញ ឲ្យវានៅវាក៏មិននៅ ។

បូលីៈ ប្រហែលប៉ុន្មានបានយើងប្រមូលគ្នាចេញ?

យានៈ ប្រហែលជាខ្ទង់៨០នាក់ជាង ។

បូលីៈ ច្រើនដែរ?

យានៈ បាទ! ច្រើន ។ អ្នកគេអត់មកប្រហែលជា៨ ទៅ១០, ២០នាក់ ។

បូលីៈ ហើយខាងណាដែលគេមកយើងទៅ?

យានៈ ខាងពួកអង្គភាពខ្ញុំ ខាសមុនហ្នឹងឯង ។

បូលីៈ ៨២?

យានៈ បាទ! វរៈ៨២ហ្នឹង ។ មាន២១, ២៣អីចឹងទៅណា ។ តាមវរសេនាតូច, អុនសេនាធំ ។ ទៅព្រៃទៅ ក៏នៅតស៊ូ ។

បូលីៈ គេនាំទៅខាងណាវិញ?

យានៈ នាំចូលក្នុងព្រៃ ព្រៃខាងអូរនោងហ្នឹង ។

បូលីៈ អូរនោង!

យានៈ អូរនោងហ្នឹងអូនឯងស្គាល់ទេ?

បូលីៈ អត់ស្គាល់ទេ! នៅម្តុំណា ស្រុកអី ខេត្តអី?

យានៈ អាហ្នឹងនៅហ្នឹង ស្រុកសៀមប៉ាងដែរ ។

បូលីៈ ហ៊ូចឹង! មិនមែនរត់មក១០០១ទេអីចឹង?

យានៈ អត់ទេ! អត់ទាន់ដឹងទេអាហ្នឹង នៅក្នុងព្រៃស៊ីក្លួច ស៊ីប្រង់ នៅហ្នឹងសិន ។ ទាល់តែឆ្នាំដែលខ្ញុំឡើងមកនេះ ឆ្នាំ២០០០ ។ ឆ្នាំ២០០០បានខ្ញុំឡើង ២០០១ បានខ្ញុំឡើងភ្នំ ។ ឡើងមកទាក់ទងហ្នឹងជាមួយខាងលើបាន ។

បូលីៈ   ១៩៨០ទេអី? ២០០១ហើយតា ឥលូវហើង២០១៣ ។

យានៈ   អ៊ូនេះចេះ ៨០ បានទាក់ទងបាន ហ្នឹងហើយ៨១ ។ ៨១ បានខ្ញុំឆ្លងទន្លេ ឆ្លងទន្លេបានខ្ញុំមក ១០០១ ។

បូលីៈ   ប៉ុន៨១ថយក្រោយ នៅក្នុងព្រៃ ស្រុកសៀមប៉ាងហ្នឹង?

យានៈ   បាទ! ស្រុកសៀមប៉ាងហ្នឹង ។

បូលីៈ   ហូបប្រង់ ។ ក្តួចហើយហ្នឹងប្រង់ ខុសគ្នាយ៉ាងម៉េចទៅ?

យានៈ   ប្រង់ហ្នឹងជាពាក្យជួនទេណា ប៉ុនប្រង់ខ្ញុំមិនដែលហូបទេ ហូបតែក្តួចទេ ។

បូលីៈ   ប្រង់ហ្នឹងយ៉ាងម៉េចទៅរូបរាងវា?

យានៈ   មើមវាចុះក្រោយ ហើយស្លឹកវាឡើងចេះ វាមានស្លឹកវាដាំលម្អដាំអីបានណា៎ ។ ស្លឹកវាដូចស្លឹកស្អាតណាស់ ។

បូលីៈ   ស្រដៀងស្លឹកដីវែងហ្នឹង?

យានៈ   វែងហើយមានមែកធាង ធាងដូចធាងដូងដែរ ស្អាត! ហើយមើមវាអត់ដែលហូបទេ ផ្លែវាប៉ុនៗមេដើង គេថាស្ងោរអីទេ តែខ្ញុំអត់ទេ ខ្ញុំដែលហូបតែក្តួចទេ ។

បូលីៈ   ហើយកាលដែលយើងរស់នៅក្នុព្រៃហ្នឹង វាពីដើម៧៩ហ្នឹង រហូតមកដល់ដើមឆ្នាំ៨០ រហូតដល់ឆ្នាំ៨០ជិត២ឆ្នាំ?

យានៈ   បាទ!

បូលីៈ   ពេលដំបូងនៅក្នុងព្រៃរហូត? ក្នុងពេលនោះមានភូមិ មានឃុំទេ?

យានៈ   អត់ទេ! យើងនៅតែក្នុងព្រៃធ្លុំបោះជំរុំនៅ ។

បូលីៈ   ប៉ុន្មាននាក់?

យានៈ   ច្រើនណាស់ ច្រើន អាហ្នឹងយើងចែកជាអង្គភាព ។ មានឧទាហរណ៍ថា កមាំងយើងមន្ទីរពេទ្យ មានវរសេនាធំ មានកន្លែងកងពលអីគេផ្សេងនោះណា ។ ហើយវរសេនាថតូច អនុសេនាធំណាជាន់តាមថ្នាក់ ។

បូលីៈ   បានន័យថាយើងនៅតាមកង តាមក្រុម?

យានៈ   បាទ! តាមក្រុមទេ ។ បើមីងគាត់មានកន្លែងគេក្នុងនោះ មេៗ ។

បូលីៈ   ប៉ុនទាំងអស់គ្នា នៅព្រៃទាំងអស់គ្នា?

យានៈ   បាទ! នៅក្នុងព្រៃទាំងអស់គ្នា ។

បូលីៈ   មិនមែនភូមិប្រជាជនទេ?

យានៈ   មិនមែនភូមិប្រជាជនទេ ។

បូលី៖ ហើយចុះកាលរស់នៅបានផ្ទះសម្បែងយ៉ាងម៉េចទៅ?

យាន៖ ផ្ទះហ្នឹងយើងធ្វើផ្ទះ កាប់ធ្វើនៅស្លឹកខាន់មា ។ អូនឯងស្គាល់ទេស្លឹកខាន់មា ។

បូលី៖ ស្លឹកខាន់មា?

យាន៖ បាទ! ស្លឹកវាវែងណាស់ ។

បូលី៖ បាទ!

យាន៖ ស្លឹកខាន់មាហ្នឹង គេដេរជាមួយជនជាតិ ជាមួយពួកឥសាន ដេរអាហ្នឹងស្លឹកហ្នឹងឯង ។
ហើយយើងខ្វះអី ឫស្សីគគោក ។

បូលី៖ ឫស្សី ហើងហ្នឹងឈើណា?

យាន៖ បាទ! ឫស្សីហើយហ្នឹងឈើ ។

បូលី៖ នៅក្នុងព្រៃអីចឹងបានន័យថាយើងចាប់ផ្ដើមកសាងការរស់នៅពីបាយទទេទៅព្រោះកាលយើង
រស់នៅសៀមប៉ាងកន្លែងដែលយើងរស់នៅ យើងឈរជើង យើងកង់ទ័ពមានស្រូវមានស្រែ
មានផ្ទះ មានសម្បែង មានភូមិឃុំ?

យាន៖ បាទ!

បូលី៖ ដល់ពេលយើងទៅនៅក្នុងព្រៃ ងារចនាសម្ព័នអស់ហ្នឹង គឺអត់មានទេ?

យាន៖ គ្រាន់តែមានអង្គភាព ។

បូលី៖ អង្គភាពរបស់ពូ?

យាន៖ បាទ!

បូលី៖ ចឹងកាលរស់នៅគឺ ដូចជាមនុស្សមករស់នៅក្នុងព្រៃអត់មានផ្ទះសម្បែង?

យាន៖ អត់ទេ! យើងចល័តនៅ ហើយនិយាយរួមដូចថាយើង គេដាក់តាមខ្សែការពារអីចឹងណា
បើយើងខ្ញុំនៅ ជាក្រុមតូចៗ ខ្ញុំចុលចិត្តនៅ អត់ចង់ប្ដូរលំនៅទេ ព្រោះអីខ្ញុំរស់នៅរតនគីរីនោះ
សំខាន់គឺហូប ដំឡូងប្រំទេ ហើយហ្នឹងក្លូច ហើយហូបផាត់ ។

បូលី៖ ដំឡូងប្រំ?

យាន៖ បាទ! ផាត់ ។ ក្ដួចវាអត់គ្រុនចាញ់ទេ ព្រោះអីវាមានជាតិពុល កាលណាយើងហូបទឹកម្សៅ
វាហ្នឹង បើពុលអីអីចឹងវាដូចសម្លាប់មេរោគអត់ចេះគ្រុនទេ បើគ្រុនងឺស្លាប់អស់ហើយ ។

បូលី៖ ហើយពូនៅក្នុងព្រៃហ្នឹង អត់មានអង្ករសោះ ឬក៏យ៉ាងម៉េច បានលាយក្ដួចហ្នឹង?

យាន៖ អត់មានទេអូន! ចុះយើងទៅរកអង្ករឯណា ។

បូលី៖ ក្នុងពេលជិត២ឆ្នាំ យើងមានដាំស្រូវដាំអីទេ? មានធ្វើស្រែចម្ការទេ?

យាន៖ យើងធ្វើម៉េចបើយួន ដើរឆ្វាត់ឆ្វែងចឹង ធ្វើអត់បានទេ ។

បូលី៖ បានន័យថា រស់នៅចល័ត?

យាន៖ បាទ! ចល័ត មិនមែនហ្នឹងថ្កល់ទេ ។

បូលី៖ ពេលណាយួនវាយយើងរត់ទៅ?

យាន៖ រត់ចេញទៅនៅនេះ ទៅនោះទៀតទៀតទៅ គឺមានចបជីកដាក់ហ្នឹងចង្កេះទេ ។ មានដំឡូង នឹងក្តួច ខ្ញុំថាអីចឹង បើដួនកាលអត់ដំឡូង ក្តួចហ្នឹងស្ងោរ ប៉ុនសម័យនោះយើងត្រៀមលក្ខណៈទេ ។ របស់ដែលយើងធ្វើហើយហូប ដូចយើងសុខសន្តិភាពចឹង គេអត់មានរាគត្បាតយួនចឹង ទាល់ចឹងយើង ធ្វើហាល ដូចដំឡូងអីយើងជីកបានមក យើងហូបតែដៃៗ អាមេៗវាចិតៗ ស្តើងៗហាល ។ ហាលឲ្យស្ងួតហើយបុកដាក់ទៅ ។

បូលី៖ ដូចខ្សែឈាង ។

យាន៖ ដេរពាក់ជាប់ខ្លួន ដេកក៏ពាក់ដែរមិនមែនត្រឹមនេះទេ ដេកក៏ពាក់អត់មានហានដោះចោលទេ ។

បូលី៖ ទ្រព្យសម្បត្តិដែលជាប់ខ្លួនយើងក្រៅពីខោអាវ គឺ មានទៃ និងចបជីកអីនឹង ។ ហើយពូអាចរៀបរាប់បានទេ មានអ្វីទៀតនៅជាប់ហ្នឹងខ្លួន?

យាន៖ នៅជាប់ខ្លួន មានអង្រឹងដេក ខោអាវ១កំប្លេ ២កំប្លេទេ មិនមានអីច្រើនទេ ហើយនឹងមុង ហើយមានតែរបស់ស៊ី បើគ្រាប់កាំភ្លើងគ្មានដង គ្មានទេ ។

បូលី៖ កាំភ្លើងអត់តែម្តង?

យាន៖ បាទ! តិចតួច! មានតិចតួច មាកាំភ្លើងណា ។

បូលី៖ កងទ័ពគេមានទេ?

យាន៖ មាន ។ ដែលចូលទៅរមៀតណា ។ ហើយបើមាន មានតែកម្លាំងដែលនៅឯមុខនោះ ។

បូលី៖ ដែលវាយជាមួយយួន?

យាន៖ បាទ! វាយទាល់យួន ដែលកម្លាំងយើងក្រោយនេះ យើងប្រើចម្រូងជីករណ្តៅ ចាក់ចម្រូង យើងប្រើអាវុធបូរាណ ។

បូលី៖ ហ៊ូ យើងធ្វើចម្រូងដែរ?

យាន៖ ខ្នារ! ខ្នារពុះ ខ្នារក្រុម ហើយអន្ទប់យើងធ្វើដើមរការអីវាយ វាយរបុស្សីបិត ចម្រឹងបុស្សី វាយធ្វើខ្នារ អន្ទប់ អាហ្នឹងបោសតែម្តង ។ ធ្លាប់មក វាជាន់កន្ទឹះធ្លាក់មក បោកតែម្តង ។

បូលី៖ ដូចក្នុងរឿងអីចឹងណ៎?

យាន៖ ហ៊ើ! ចូលអត់បានទេ តែចូលព្រោះអត់ប្រាប់ ដឹងតែរឿង ។ ហើយកាលនោះ យើងសុទ្ធតែមាន បើថាអ៊ូដឹងតែយួនចុះមកហើយ ពុម្ពជ័រឆេក់ ។ គេស្លក្នុងម្នាក់គេឲ្យ១ដប មានកន្លែងគេស្លឲ្យ ជនជាតិបងប្អូនជនជាតិនោះស្ល ។

បូលីៈ ហើយយើងយកមកជ្រលក់អាចុង?

យានៈ អាហ្នឹង ពេលគេថាទាល់ណា អាខ្មាំងចុះមកដឹងមុខសញ្ញាគេចាក់ អាហ្នឹងឯង ។

បូលីៈ អ្ហូ! ដាក់ភ្លាមៗតែម្ដង?

យានៈ បាទ! ជ្រលក់ភ្លាម ចាក់ភ្លាម ។

បូលីៈ បើទុកយូរវាអស់ប្រសិទ្ធភាព?

យានៈ បាទ! អស់ប្រសិទ្ធិភាព ។

បូលីៈ ខាងបងប្អូនជនជាតិ គាត់អ្នកស្ង?

យានៈ អ្នកស្ង ។

បូលីៈ ពូដឹងពីគ្រឿងផ្សំវា អត់ដឹងទេ?

យានៈ ដឹងវល្លិ៍ឈើអីៗ ខ្ញុំអត់ស្គាល់ អត់ដឹងទេ តែគ្រាន់តែដឹងថា បន្សាប ងាយបំផុត គឺខ្ទាញ់ក្ដាម យើងនេះឯង ។ ប៉ុន្ដែបើគេដាក់ខ្ទាញ់ក្ដាមនៅក្នុងហ្នឹងទៀត អស់ហើយ ។

បូលីៈ សាបអស់ប្រេងរលីង?

យានៈ អត់មារឿងអីត្រូវបន្សាបបានទៀតទេ ។

បូលីៈ បើសិនដាក់ខ្ទាញ់ក្ដាម គេលាយជាមួយអាចម្រុងជ័រឆក់ហ្នឹង?

យានៈ ដល់យើងយកខ្ទាញ់ក្ដាមយកទៅលាប អត់មានប្រសិទ្ធភាពដែរ ។

បូលីៈ អាហ្នឹងបើសិនជាយើងជាន់ ស្លាប់ភ្លាមៗ ឬយ៉ាងម៉េច?

យានៈ វាចុក អាហ្នឹងមិនយូរដែរ បាទ! វាចុកណា វាជាតិពិស ។ តាមមើលក្បាលមានទាំងដើមឈើ មាន ទាំងពីក្បាលពោះវែកស្មោរណា ។

បូលីៈ ចុះពូនៅក្នុងព្រៃចឹង ពេលដែលលយើងសម្រាក ពេលយប់សម្រាកយ៉ាងម៉េចទៅ?

យានៈ យើងអ្នកដេកអង្រឹងបានដូចខ្ញុំថាអីចឹង អ្នកណាដេកអង្រឹងបានដេក អ្នកណាអត់យើងធ្វើគ្រែ ឫស្សី ។ ឫស្សីយើងពុះរនាបទៅ ។

បូលីៈ អីចឹងមានដេកអង្រឹងលើគ្រែឫស្សី មានអ្នកដេកផ្ទាល់ដីទេ?

យានៈ អើបើខែប្រាំង យើងច្រើនតែដេក ផ្ទាល់ៗដីហើយ ។

បូលីៈ ប៉ុនមានអីក្រាលពីក្រោម ក្រាលទេ?

យានៈ ជួនកាលអត់ទេ ភ្លាមជួនកាលដូចរត់ប្រផាត់ ប្រភឹងអី ដេកជួនការយកទៅដេកកកាច់ស្លឹក ក្រក្លបមកក្រោបពីមុខ ដេកទៅ ខ្លួននៅកណ្ដាលវាលក៏មានដែរ ។ អាហ្នឹងយើងរត់ប្រផាត់ ប្រភឹងហើយណា ។ រត់ចោលជំរុំ ចោលផ្ទះអាដែលយើងធ្វើតូចៗចឹងទៅណា ។

បូលីៈ ពេលយួនវាយ?

យាន៖ បាទ! យើងរកអីទាន់ពេលយើងរត់ទៅហើយយប់នោះ មានតែដេកកណ្ដាលវាលហ្នឹងឯង ។
បូលី៖ រត់ហ្នឹងយើងចោលរបស់ របស់យើងអស់រលីង?
យាន៖ បាទ!
បូលី៖ មានមុងមានអីទេពូយប់ឡើង?
យាន៖ មុងអត់មានទេ ។ មានដុតភ្លើង ដុតអីហ្នឹង ។
បូលី៖ ដុតភ្លើងដែរ?
យាន៖ បាទ!
បូលី៖ យើងដុតភ្លើង យើងអត់ខ្លាចយួនឃើញទេ?
យាន៖ ចុះយប់ឡើង យើងនៅនេះដែរណា ។ បាទ យើងដុតដែរ កន្លែងណាយើងដុតបានយើងដុតទៅណា ។
បូលី៖ ចុះពូថាជីកទឹកពុលអីនោះយ៉ាងម៉េច?
យាន៖ អាហ្នឹង ខ្ញុំឡើងមកភ្នំហើយ ។
បូលី៖ ឡើង១០០១ហើយណា?
យាន៖ បាទ! ខ្ញុំចូលមកទន្លេល្អៅហើយណ៎ ។
បូលី៖ អ៊ូ! សុំសួរបកទៅខាងនោះវិញសិន ហើយកាលដែលរស់នៅអីចឹង មានមនុស្សស្លាប់ដោយសារជំងឺ ដោយសារអីទេ?
យាន៖ នែ៎ក! មានតាអូន មានតាអ្នកក្រោយ ព្រោះអ្នកក្រោយឲ្យគ្នានៅមន្ទីរនៅអីចឹង សំខាន់ការហូបចុកអត់បានគ្រប់គ្រាន់ដូចអ្នកមុខទេ ។ អ្នកមុខចេះតែរកនេះរកនោះ ផ្ដល់អ្នកក្រោយទេ ព្រោះយើងនៅមុខចឹង ជួនកាល អើកាលនោះជំនាន់ហ្នឹងក្របីសម្បូរណាស់ សត្វព្រៃអីណា ចឹងបានមកផ្គត់ផ្គង់ឲ្យអ្នកក្រោយ ។ ចឹងគ្រោះថ្នាក់ច្រើនតែអ្នកក្រោយទេដែលស្លាប់ ដូចថាវាមិនមានកម្លាំងកំហែង មានជំងឺអីទៅណា ។
បូលី៖ ប្រហែលពូអាចវាយស្មានបានទេ អ្នកដែលរស់នៅក្នុងព្រៃទាំងកម្លាំងទ័ពខាងមុខ ទាំងអ្នកក្រោយហ្នឹងណា ប្រហែលជាប៉ុន្មានទៅចូលខ្ទង់ពាន់ទេ?
យាន៖ ពិបាកដែលវាមួយកងពលហ្នឹងវាចូលកន្លែងហ្នឹងឯង ៨០១ហ្នឹង ។
បូលី៖ ពីព្រោះមួយចំនួនដែលខ្ញុំសាកសួរគេណាពូ មួយចំនួនបែក៧៩ វៀតណាមវាយចូលភ្លាមគេឆ្លងទន្លេមក១០០១ភ្លាម ។
យាន៖ បាទ! អាហ្នឹងហើយ អាហ្នឹងដូចក្បាល គេថារឿងក្បាល ។
បូលី៖ តែក្បាលទេ?

យានៈ ហ្នឹងហើយ រឿងអ្នកមុនៗ

បូលីៈ តា០៥ មានដែលឃើញទេកាលហ្នឹង ពេលពូនៅក្នុងព្រៃ?

យានៈ បាទ! ខ្ញុំអត់បាននៅជាប់ជាមួយគាត់ទេ គាត់នៅដោយឡែកគាត់នៅកងពល ខ្ញុំនៅតែជាមួយ បងប្អូនៗ បងប្អូនគាត់នៅវរសេនាធំៗ

បូលីៈ ប៉ុន្តែតា០៥ គាត់អត់ដែលចុះមកមើលអ្នកដែលនៅក្នុងព្រៃនេះទេ?

យានៈ វាដូចខ្ញុំថាចឹង កម្លាំងចែកទៅតាមមុខសញ្ញា អីចឹងអាហ្នឹងគេថា មុខសញ្ញាណៅខាងណា អាហ្នឹង គាត់ហៅទៅប្រជុំហើយណា មេៗអនុសេនាធំ អនុសេនាតូចហើយណាៗ ហៅទៅប្រជុំយើង យុវជន យើងនៅក្រោយ យើងមិនដែលបានទៅកន្លែងគាត់ទេៗ ហើយមានអីដូចថានោះខាង ខ្ញុំមានសាច់ ឬក៏មានម្ហូបអី មានអង្ករអីដែលយើងបានពីមុខទៅ ទៅហើយយកទៅឲ្យផ្គត់ផ្គង់ មេៗ

បូលីៈ អ្នកនៅខាងលើ១០០១ហ្នឹង គេមានប្រជុំបញ្ជូនអង្ករ បញ្ជូនអីទៅឲ្យយើងទេ?

យានៈ ទៅខាងកើតទន្លេៗ

បូលីៈ អ្នកនៅខាងលើភ្នំដងរែកនេះ ដល់ទល់ដែនហើយនេះៗ

យានៈ ហ៊ូ! អាហ្នឹងបើចេះ បើពួកក្រោយអាហ្នឹង ពួកខ្ញុំឆ្លងមុនណា ខ្ញុំ១៩៨០ឆ្លងទន្លេៗ ខ្ញុំឆ្លងអត់ ពិបាកហែលទេ លួចទូកជី ឈុន ឆ្លងៗ ខ្ញុំដើរមកគោកមានអីទេ យើងចេកយើង ចេកខ្ចីៗ ហ្នឹង ចិតៗហាលវាទៅដល់យកទៅស្ងោហូបហ្នឹងចត់ៗហ្នឹង ខ្ញុំហូបតិចៗ ដើរមក ខ្ញុំដើរខែ៥ ព្រីងយើងទុំ និងផ្លែធ្លក បានអាហ្នឹងឯងហូបព្រីងទុំហូបផ្លែធ្លកហ្នឹងឯងៗ មកដល់ទន្លេល្ពៅ ចាប់ ផ្ដើមហៅទន្លេល្ពៅរវាងក្រោមហ្នឹង ជាប់ព្រំដែនយើងហ្នឹង កម្លាំងគេទៅទទួល ទៅទទួលក៏មិន មែនបានយកអង្ករទៅចែកឲ្យបានគ្រប់គ្នាបានអង្ករ១០នាក់អីមួយកំប៉ុង បបរណាៗ

បូលីៈ ហ៊ូ! ខាងលើគេចែកឲ្យហ៎?

យានៈ អាហ្នឹងខាងលើគេអ្នកចែកឲ្យ ទៅទទួលណាៗ ហ្នឹងហើយទៅយកបាន១កំប៉ុងៗម្នាក់អីចឹងៗ ចឹងបានខ្ញុំថាបានមកដល់ដីលាវ ចូលដល់ដីលាវហើយណា គេហៅគណៈធ្លកៗណាៗ លាវវាដឹង ដែរវាធ្លាប់ដែរៗ មកដល់វាអត់មានដាំអី វាដាំបាយឲ្យតែម្ដង ឲ្យពួកខ្ញុំណៅស្ងៀមៗ ពួកហ្នឹង ហើយបាយឆ្នាំងប៉ុណ្ណេះ គ្នាមិនដល់១០នាក់ផងប៉ុណ្ណឹង ហើយនិយាយទៅគ្នាបុករំដេង ហូបៗ ទល់តែអស់ មិនដែលបានស្គាល់បានបាយហូប(និយាយទូរស័ព្ទ)ៗ មកដំណាក់កាលនេះហើយ ខ្ញុំនិយាយឲ្យអស់កេរ្តិ៍អស់ខ្មាស់ មានអ្នកខ្លះមកស្ដាប់ដូចថាហូបបាយៗ ធម្មតាក្រពះយើង អត់ បានទទួលបាយ ដូចយើងហូបឆ្អែតទៅ មិនប្រតិកម្ម អត់ជឿទៀត! បានធម្មតាលាវកាលហ្នឹង ក៏យកពីការខបត្ថម្ភ ពីខ្មែរក្រហមដែរៗ យកអង្ករពីតាពត ហូបដែរ អីចឹងគាត់ប្រាប់ថា ខ្ញុំក៏

យកមកពីហ្នឹងដែរ បងមិនបាច់យកទៅទេ តែប៉ុណ្ណោះដើរដឹកថ្ងៃត្រង់ដល់ហើយ ។ នៅច្រកអន្លុរដាក់ស្ពាយទៀត បំណាច់យើងអត់ណា គេប្រាប់ហើយ យើងមិនជឿទៀត យើងសុំគេច្រក ១០គំប៉ុង ឲ្យមាននៅហ្នឹងចង្កេះចឹងណា ។ ដាក់ស្អែង យើងដើទៅមិនបាន១ព្រឹក ផងឡើងដល់លើភ្នំ ដល់ឃ្លាំងគេហើយ ។

បូលី៖ នៅតែខ្លាចគេកុហក?

យាន៖ បាទ! ខ្លាចគេកុហកព្រោះដាច់បាយ មិនដែលបានបាយហូបទេ ។

បូលី៖ មានអ្នកស្លាប់ដោយសារហូបទេពូ?

យាន៖ មាន ។

បូលី៖ ហូបច្រើនពេក?

យាន៖ បាទ! នេះមិនសួរស្រុករគាត់ ភូមិភាគកណ្ដាល! ខ្លះហើម ត្រូវបាយហើម ប៉ុន្មែអ្នកខ្លះគេដឹង គេហូបបបរអីសិនគេសម្រួលណា ហូបតិចតួចៗសិន ។ អ្នកខ្លះអត់នេះ គិតរិបយកពីឈ្នះដៃ ហើយក្រពះយើងអត់ធ្វើការ ស្លាប់ខ្លះៗមែនណា ក្នាយើងស្លាប់ដោយសារមកដល់បាយហើយស្លាប់ទៀត ។

បូលី៖ ស្លាប់ដូចគាដូជក់?

យាន៖ ហ្នឹងហើយ ។ ស៊ីវាហល់ បាទ! អ្នកខ្លះទៅគេនឹកឃើញ តាមផងម៉ែឪថា ពេលអត់បាយហើយ ពេលមកជួបបាយវិញយកកឲ្យយើងហូបបបរ ហូបអីចឹងទៅ ។ អាហ្នឹងហូបតាមហ្នឹងទៅ អត់អីទេ ។ ហើយកាលហ្នឹងវាសម្បូរមួយជំនាន់ សម័យនោះ មិនថាអីទេ ជំនួយសព្វបែបយ៉ាង អង្ករដំណើបក៏មិនខ្វះ ស្ករក៏មិនខ្វះដែរ ។

បូលី៖ បានន័យថាពូឆ្លងរត់មក១០០១ ទន្លេល្ពៅហ្នឹងពូរត់តាមដីលាវ ឬយ៉ាងម៉េច?

យាន៖ ចូលកាត់ដីលាវ ។

បូលី៖ ម៉េចក៏មកមិនតាមដីខ្មែរ?

យាន៖ យើងកាត់វាត្រង់ ។ បើយើងវាង ដីខ្មែរយើងវាកែល យើងដើរកាត់ដីលាវត្រង់ ។

បូលី៖ អានេះស្រុកផ្នែបណាពូ ។

យាន៖ បាទៗ!

បូលី៖ អានេះថាឡាបរិវាត់ ។ នេះ!

យាន៖ មុំបី!

បូលី៖ មុំបី! ១០០១ណាពូ ។ ពូដើរកាត់ពីណាទៅបានៗមកឆាប់ដល់ពីនេះទៅចេះ?

យាន៖ បាទ! នេះចំហៅភូមិខ្ទឹម យើងកាត់ត្រង់នេះ កាត់មកទន្លេល្ពៅណា ។

បូលីៈ ឆាប់ដល់ណា ។

យានៈ ឆាប់ដល់វ៉ារកែល ។

បូលីៈ វកែល?

យានៈ បាទ! វ៉ាងមួយខ្ទឹមនេះទៀត ។

បូលីៈ វែងណាស់ ។

យានៈ ហ្នឹងហើយ បើយើងកាត់ដុំព្រាល មួយដុំខ្ទឹមនេះបានឆាប់ បានឆ្លងឆាប់ចូល ។

បូលីៈ អ្នកដែលគេឆ្លងតាំងពី៧៩ គេឆ្លងតាមដីខ្មែរ?

យានៈ មិនដឹងដែរ! ប៉ុន្តែគ្រាន់តែនាំខ្ញុំ នាំកាត់នេះដែរ ។

បូលីៈ កាត់ដីខ្មែរតិចដែរ ។

យានៈ បាទ! កាត់ដីលាវ ចូលដីលាវដែរ ។

បូលីៈ អាចហេតុផលដែលថាកាត់ដល់ដីលាវដោយសារ ខាងដីខ្មែរ យួននៅទេ?

យានៈ មាននៅចំណុចៗដីស្រែកង់ទ័ព នៅល្បៀក្រុខិក អាកន្លែងនៃកខ្ទឹមនេះក៏មានដែរ ។

បូលីៈ យួនហេ៎?

យានៈ យួននៅដែរ ប៉ុនយើងដើរប្រលោះ ប្រលោះវ៉ាល និងខ្ទឹម ។

បូលីៈ ដើម្បីចៀសកុំឲ្យជួបយួន?

យានៈ បាទ! យើងដើរកាត់កណ្ដាល បើយើងមកទីនេះវ៉ាកេវមកចន្លោះពីរ វ៉ានៅសងខាង អានេះវ៉ា នៅតែខ្ទឹមទេ ។ បើព្រាលវ៉ាអត់នៅទេ វ៉ាមកគ្រាន់ទៃចល័តម្ដងៗទេ ព្រាលនេះ បន្ទាប់លាវ នេះ កងទ័ពលាវទេខាងព្រាល ។

បូលីៈ ពូមកលើ១០០១ហ្នឹងប្រហែលជាខែប៉ុន្មាន ឆ្នាំប៉ុន្មាន?

យានៈ ដូចខ្ញុំថាអីចឹងវ៉ាឆ្នាំ៨០ ។

បូលីៈ ប៉ែតគត់ ឬប៉ែតមួយ?

យានៈ ប៉ែតសិប ។ បាទ! បើ៨១បានខ្ញុំរៀបអន្តភាពហើយ ។

បូលីៈ ៨០ មកដល់១០០១?

យានៈ មកដល់១០០១ ។

បូលីៈ មកដល់១០០១ ខ្ទង់ខែប៉ុន្មាន?

យានៈ ខែ៥ ។

បូលីៈ ខែ៥, ៨០ហេ៎ពូ?

យានៈ បាទ!

បូលីៈ   បែកមកភា៧៩?

យានៈ   បាទ!

បូលីៈ   បែកមកភា៧៩ ដល់មកភា៨០, វា១ឆ្នាំគត់ហើយ ។

យានៈ   បាទ!

បូលីៈ   ដល់ខែ៥ វា១ឆ្នាំ៤ខែ ។ អាចថា១ឆ្នាំ ៥ខែទេ?

យានៈ   បាទ!

បូលីៈ   បានន័យថាពូនៅក្នុងព្រៃ១ឆ្នាំកន្លះ?

យានៈ   ១ឆ្នាំជាង ។

បូលីៈ   បាទ! ១ឆ្នាំជាង បានឡើង១០០១តាមក្រោយ ។

យានៈ   បាទ!

បូលីៈ   ពេលដែលពូមកហ្នឹង ប៉ុន្មាននាក់ មកតាមពូដែរទាំងអស់?

យានៈ   មកគ្នាជាង៣០០នាក់ ។

បូលីៈ   ច្រើន?

យានៈ   ច្រើន! ចុះ១វរសេនាធំ ។ មកមួយវរសេនាធំហ្នឹងឯង ។

បូលីៈ   ក្នុងនោះមានស្រីមានប្រុស មានក្មេងមានចាស់?

យានៈ   មកទាំងអស់ មានក្មេងមានចាស់ ។ អីចឹងបានសំណាងហើយអ្នកដែលមកមុននេះ ។ អ្នកដែលមកក្រោយបានវេទនា ។

បូលីៈ   វេទនាយ៉ាងម៉េច?

យានៈ   ធម្មតាគេដឹងអស់ហើយ! គេរក្សាទុកសុវត្ថិភាពបាន វេទនា ។

បូលីៈ   វេទនាយ៉ាងម៉េច?

យានៈ   ធម្មតាគេដឹងអស់ហើយ ដឹងថាទុកអីគេរក្សាទុកសុវត្ថិភាព យើងចាក់សោ ចាក់អីចឹង មានអ្នកយាមកាមលួចបានទេ ។

បូលីៈ   យួនហ៎?

យានៈ   បាទ! ដល់ចឹងហែល គ្នាធ្វើក្បួនហែល ហើយនាំគ្នាមកចំខែ១១,១២ ចំខែរនាវហ្នឹងទេ ខ្ញុំទៅទទួល ខ្ញុំទៅទទួលនៅស្រែខ្សាច់ បាទ! គិចថាយើងហូបក្តួច ហូបប្រង់ ណាអូនណា អ្នកខ្លះមកដល់លើគោកហើយ អត់ៗដើបរួចទេ ស្ពឹកដើរអត់រួចទេ ។

បូលីៈ   ត្រជាក់ពេក?

យានៈ ត្រដាក់ស្តុកយកតែម្តង ។ ខ្លះមកដល់គោកដាច់ខ្យល់លើគោកក៏មាន ខ្លះរបូតក្បូនវាត្រដាក់ពេក ណា អណ្តែតតាមទឹកក៏មាន ច្រើនណា៎ ។

បូលីៈ លង់ទៅ!

យានៈ ស្លាប់ច្រើនណា៎ ទាំងស្រីទាំងប្រុស ត្រដាក់បើទឹកអត់ត្រដាក់អត់អីទេ ហែលឆ្លងបាន ព្រោះអី យើងហែលខែ១១,១២ ទឹកនៅច្រើនណាស់ ។

បូលីៈ បើយើងឆ្លង ឆ្លងកន្លែងនេះហើយណ៎?

យានៈ បាទ! ហ្នឹងហើយឆ្លងចំហ្នឹងឯងមិនថាយើងឆ្លងក្រោមកោះហ្នឹង នៅមុំកោះហិបកោះអីពេល ឆ្លង ។ ទាល់ឆ្លងពីហ្នឹងមក មិនដឹងថាចុះ មិនមែនធ្លាក់ចុះគឺឡូទេ ហែលមកមិនមែនយើងហែល បានត្រង់ឯណាធ្លាក់មកក្រោមទៅទៀត ។

បូលីៈ ត្រូវហើយ! ព្រោះទឹកវាហូរ ។

យានៈ ព្រោះយើងមានកម្លាំងណាធាក់ទឹក មានតែបណ្តែតទឹកទេ ខ្លះអត់ចូលប្រាំងផង ។

បូលីៈ អត់មានកម្លាំង កាយចូលប្រាំងទេ ។

យានៈ អត់មានកម្លាំងកាយ ។

បូលីៈ ពេលដែលពូឡើងមកដល់១០០១ហ្នឹង នរណាគេអ្នកនាំផ្លូវ ។

យានៈ ខ្ញុំអត់ស្គាល់ មិនដឹងនរណានាំទេ អត់ដឹងទេថានរណាគេអ្នកបានមកទេ យើងមួយគ្រាន់តែដឹងថា តាមត្រីវិស័យ គេសម្គាល់ថាមកដូចកើតប្រឆាកជើងចឹងណាអូនណា ។ ចឹងមកតាមត្រីវិស័យ ។

បូលីៈ ទម្លុះព្រៃ?

យានៈ បាទ! កាត់តាមត្រីវិស័យ តាមគេដូចថាគេគូរលេខទៅណា ឲ្យមកចំណុចនេះ មកចំណុចនេះ ដាក់ត្រីវិស័យលេងត្រង់នេះៗ គេទៅមេចឹងៗបើអត់មានអ្នកនាំទេ ។

បូលីៈ ផ្លូវដែលយើងដើរហ្នឹង វាមានដានចាស់ ផ្លូវហ្នឹង?

យានៈ អត់ទេដើរតាមព្រៃតែម្តង អត់មានដានចាស់ទេ ។

បូលីៈ ចុះបើមានព្រៃញ៉ុកខ្លាំង?

យានៈ អត់ទេ! វាលមានដីទំនាប ដីខ្ពង់រាបដីទំនាបចឹងគា តំបន់នោះ មិនមែនព្រៃណែនចេះទេ ។ បាទ! ខ្ញុំដើរមកអត់មានព្រៃណែនចេះទេ ហើយមកឆ្លងទន្លេមេគង្គហើយមកឆ្លងទន្លេ ប៉ុន្តែ មិនដឹង ទន្លេទេ ខ្ញុំឆ្លងហែល ប៉ុន្តែយើងហែលពីនេះទៅផ្លូវដែរទន្លេហ្នឹងណា ។ ពូថាយួនទៅវាយ ទៅ វាយ នៅអូរអណ្តូងផង ។ យួនទៅវាយពួកខ្ញុំកំពុងតែដាំបាយហូប ដាំបាយហូបដាក់ខ្សែ ត្រៀមចឹងទៅ ។ មានអីបើយើងរត់យកតែអាយុរៀងៗខ្លួនទៅចឹងឯង ប៉ុនអត់មានស្លាប់ មាន បាត់បង់អីទេ យួនវាគ្រាន់តែបាញ់វាមិនតាមអីទៀត ។

បូលីៈ បានន័យថាអត់មានតាមផ្លូវចាស់ទេ?

យានៈ អត់ទេ! គឺយើងដើរតាមត្រីវិស័យតែម្ដង។

បូលីៈ សុទ្ធសាធតែម្ដង?

យានៈ បាទ!

បូលីៈ ពេលដែលមកដល់លើ១០០១ហ្នឹង ពេលហ្នឹងគេឲ្យយើងសម្រាក ឬរៀបចំកម្លាំងភ្លាម?

យានៈ ខ្ញុំមកបាន៨ ទៅ១០ថ្ងៃ គេឲ្យខ្ញុំចុះមកទទួលកម្លាំងក្រោយទៀត។

បូលីៈ ហ៊ុំ គេចុះមកទទួលដែរ?

យានៈ បាទ! មកវិរៈ ខ្ញុំមកមួយកងវិរៈ ឈ្មោះតារុនៗនោះស្លាប់បាត់ហើយ។ បាននៅស្រុកខ្ញុំជិតខ្ញុំដែរ។ បាទ! អូនឯងធ្លាប់ហូបបាយហើយយើងមកហូបក្តួចទៀត។

បូលីៈ បកក្រោយហូបក្តួចទៀត?

យានៈ បាទ! ចុះយើងចូលមកជ្រៅ ចូលទៅចាំគេម្ដុំណា ខ្ញុំភ្លេចអស់ហើយ ដល់ចឹងយើងមិនដាច់ពីរយៈអ្នកលើមក។ មានអី មានអីហូបក្តួចហូបនែកត្រពាំងហីរ។

បូលីៈ ហ៊ុំ! ដរដែរអីចឹង?

យានៈ បាទ! ចុះដាច់យើងមាននរណាជួនឲ្យ យើងមករាប់ខែ មកចាំកម្លាំងផងយក។ បាទ! មកបាន៨ទៅ៥នាក់។ ៨ ទៅ១០នាក់វាស្មាក់តាមផ្លូវហ្នឹងណា ឲ្យតែឃើញមើលដានជើងមើលឃើញចុះមានស្បែកជើងណាពាក់។ មើលឃើញអានេះសម្គាមហើយតាមមើល អាចៗសត្វ ដល់នេះ ដានជើងមនុស្សណា បានខ្ញុំឡើងមកទៀត។

បូលីៈ ពូទៅមកៗ ប៉ុន្មានដងបាន?

យានៈ បាទ! អាហ្នឹងហើយបានទទួល ខ្ញុំមកបីដង។

បូលីៈ បីដង?

យានៈ បាទ! អាហ្នឹងហើយមកទទួលណា។ ហូរកម្លាំងគេថា ឆ្លងមកទៀហើយ បានយើងចុះមកទទួលទៀត។

បូលីៈ ម្ដងទទួលបានប៉ុន្មាននាក់?

យានៈ បានប្រហែល៨ ទៅ១០នាក់អីទាំងអស់ទៅ។

បូលីៈ តិចៗដែរ?

យានៈ បាទ! តិច។

បូលីៈ មួយជំនាន់ពូមកបានច្រើន?

យានៈ បានច្រើន។

បូលីៈ   រាប់រយតែម្តង?

យានៈ   បាទ! រាប់រយ ៗ មកនេះម្តង មកប្រុយៗចឹងទៅណា គេទទួលតាមអត្តភាពគេបាទ! គ្រាន់តែអត្តភាពនេះទៅទាក់ទងនោះមក គេចេះតែប្រាប់ហើយទៅណា ៗ កងនេះទៅប៉ុណ្ណេះនាក់ កងនេះទៅប៉ុណ្ណេះអ្នក ហើយមកឃើញត្រង់នេះ បានឃើញប៉ុណ្ណឹងណា ៗ ពាក់កណ្តាលអីចឹងទៅណា ៗ

បូលីៈ   ដែលតួលេខប្រាប់មកថា ដល់ឃើញដាក់ស្តែងប៉ុននេះ ៗ

យានៈ   បាទ! មក៨ ទៅ១០, មក២០នាក់ចឹងទៅ ៗ

បូលីៈ   បាត់ដោយសារអីទៅ?

យានៈ   ដូចខ្ញុំថាអីចឹង ខ្លះហែលតាមក្នុងទន្លេ ខ្លះមកដល់ច្រាំងហើយយួនចាប់បានក៏មាន យកដាក់ទាំងគុក(ស្តាប់ពុំបាន)ក៏មាន ៗ

បូលីៈ   (ស្តាប់ពុំបាន) នៅឯស្ទឹងត្រែងឯនោះ?

យានៈ   បាទ!

បូលីៈ   បន្ទាប់ពីទទួលគេពាដងហើយ គេចាប់ផ្តើមរៀបចំកម្លាំងយ៉ាងម៉េចទៀត?

យានៈ   បាទ! ខ្ញុំមករៀបនៅ គេហៅថាកងអន្តរាគមន៍ ៗ

បូលីៈ   លេខប៉ុន្មាន?

យានៈ   កងអន្តរាគមន៍ លេខប៉ុន្មាន ខ្ញុំភ្លេចបាត់ហើយ ៗ

បូលីៈ   ៩៨០?

យានៈ   ៩៨១ ៗ នេះហើយវរសេនាធំ៨១ ៗ

បូលីៈ   កងពល៨០១ដដែរ?

យានៈ   បាទ! ប៉ុនខ្ញុំនៅ៨១ លែងនៅ៨០២ហើយ លែងនៅវរសេនាធំ៨០២ហើយ ៗ

បូលីៈ   ៨២ហើយ ៗ

យានៈ   ៨២ហើយ! បានខ្ញុំមកនៅ៨១វិញ ៗ ហ្នឹងហើយហៅកងអន្តរាគមន៍ ៗ

បូលីៈ   មានន័យថាម៉េចទៅកងអន្តរាគមន៍?

យានៈ   កងអន្តរាគមន៍ បានន័យថាកន្លែងក៏ទៅវាយបានដែរ ចល័តវាយថាមុខសញ្ញាណាហៅទៅបញ្ជូនណាមួយ ក្រុមអន្តរាគមន៍នោះទៅ គេត្រូវការហើយណា ៗ

បូលីៈ   នៅលើភ្នំ១០០១នេះ នរណាគេជាអ្នកគ្រប់គ្រង?

យានៈ   គ្រប់គ្រង អាហ្នឹងដូចនិយាយអីចឹងវាតាមផ្នែក វាច្រើនកងពលណាអូន ៗ

បូលីៈ   មិនមែនតា សុន សេនទេពូ?

យាន៖ កន្លែងហ្នឹងវា មុខសញ្ញារបស់គាត់ដែរ ពុស្សួរថាខ្ញុំគ្រាន់តែពុទេណាអូន មិនដែលឃើញទេ ។ វា ចម្រុះហើយ កន្លែងទៅហ្នឹងគ្រប់កងពលដែលទៅហ្នឹងណា ។

បូលី៖ ពេលដែលរៀបចំហើយ គេបញ្ជូនយើងចុះមកធ្វើការខាងក្នុង?

យាន៖ បាទ! ដូចខ្ញុំថាអីចឹងមកធ្វើនៅឆែប ។

បូលី៖ អូ៎! មកធ្វើណោឆែបនែ?

យាន៖ បាទ!

បូលី៖ ពូមកខាងឆែប! ហ្នឹងពូនៅ៨១ហើយ ចុះមកឆែបព្រះវិហារនែ៎កពូនែ៎ក?

យាន៖ បាទ!

បូលី៖ ចឹងព្រះវិហារនេះ ៨០១អ្នកធ្វើ?

យាន៖ បាទ! ម្តុំឆែបហ្នឹងរហូត រហូតដល់ម្តុំម្លូព្រៃ ។

បូលី៖ ម្លូព្រៃហ្នឹង នៅឆែបដែរពូ?

យាន៖ ឆែបដែរ ។

បូលី៖ អានេះវាធំបន្តិច ។ ពូធ្វើការតែឆែបម្តុំហ្នឹងទេ ឬក៏គេឲ្យទៅធ្វើការនៅណាទៀត?

យាន៖ អត់ទេ! ម្តុំឆែប ។

បូលី៖ តែម្តុំឆែបហ្នឹងទេ?

យាន៖ បាទ!

បូលី៖ អានេះវា១០០១ណាពូ អានេះកងពល៨០១របស់ពូណា?

យាន៖ បាទ!

បូលី៖ ពូនៅ៨១មិនចឹងនែក?

យាន៖ បាទ!

បូលី៖ ចឹង៨០១ ចុះមកធ្វើការនៅក្នុងខេត្តព្រះវិហារដែរ មានឆែប មានអីចឹងទៅណ៎ពូណ៎ ។ ដាំ កូប្រានុ្ដអីមានទេពូ?

យាន៖ ដូចថាដងផ្ចិត ដងអីដែលខ្ញុំកាត់ហ្នឹង គឺកន្លែងហ្នឹងហើយ ។ ដងផ្ចិត អីគេហៅអីទៀតទេ ភ្លេច ហើយ!

បូលី៖ ដែលគេឲ្យយើងចុះមកធ្វើការហ្នឹង យើងធ្វើការយ៉ាងម៉េចពូ?

យាន៖ ទី១ យើងដើរសើបមើលផ្លូវឃ្លូនដើរ ហើយមួយយើងវាយឈ្លប ហើយឈ្លបវាឃើញថា បន្ទាយថាដូចនៅណា នៅសន្ធានៅអីចឹងទៅណា យើងទៅវាយកផ្លោងដាក់ ហើយក៏ចេញមក យើងវាយស្ទាក់តាមផ្លូវឆែបហ្នឹង ។

អ្នកជិតខាងៈ បាញ់ពីចម្ងាយ រត់ទៅរាយការណ៍ប៉ុណ្ណេះៗ ។

យានៈ បាញ់ពីចម្ងាយ ហើយរត់មករាយការណ៍ផាប់ទីនេះ ផាប់ទីនោះ ។

អ្នកជិតខាងៈ បើយើងមិនរាយការណ៍ឲ្យគេ គេឲ្យយើងទៅទៀត ។

បូលីៈ ប៉ុន្តែកាលដែលស្លាប់ប៉ុន្មានដែលច្បាស់លាស់នោះ គឺយើងអត់ដឹងទេ?

យានៈ បាទ! អត់ដឹងទេ ។ គ្រាន់ពេលគេបាញ់ទៅ គ្រាន់តែមាត់មនុស្សច្រើនណាស់ ព្ទសូរអ៊ូអែអែចឹងណា ។ បាទ!ថា ចំហើយ ប៉ុនថាស្លាប់ យើងរាយការណ៍ប៉ុណ្ណេះៗ គេដកទៀត ប៉ុនយើងបានបាញ់រួចហើយ យើងស្ទាក់បាញ់ឡានចឹងទៅណា ។ ខ្ញុំថាកម្លាំងជិះប៉ុណ្ណេះៗ គេដាក់ទៅផាប់ប៉ុណ្ណេះរាយការណ៍ ។ យើងមាននរណារាប់បាន បើរាប់បានទាល់តែយើងចុចមីន ។ យើងចាប់ចុច អាមីនគោន អាហ្នឹងបានយើងរាប់ដឹងចំនួនខ្មោច ។ យើងចុចមីនគោន អូនឯងគិតមើល ៧គ្រាប់នោះ ហើយឃួនដើរតែ២០នាក់ដាង ។

បូលីៈ ចុចយ៉ាងម៉េចពូ?

យានៈ ចុចមានមានកិប មានអន្ទក់វា យើងដាក់ខ្សែវា របស់ចិនវាមិនមែនរត់ខ្សែភ្លើងទេ វារត់បាញ់អារំសេវនោះបាញ់តាមខ្សែតែម្តង ។

បូលីៈ វាឆេះចឹងតែម្តង?

យានៈ ឆេះចឹងតែម្តង តាមខ្សែស្នួលវាហ្នឹង ។

បូលីៈ ទៅដល់ហ្នឹងផ្ទុះបណ្តោយ?

យានៈ បាទ! ទៅដល់កន្លែងមីនគោនផ្ទុះតែម្តង ។ គ្រាន់តែពឹប ផ្ទុះតែទូង ។ លឿនណា!

ដានីៈ លឿនតែម្តង!

យានៈ បាទ! មិនមែនឆេះដូចអាឆេះយឺតអាជីក ។

ដានីៈ កាំជ្រួច?

យានៈ បាទ! ឆេះស៊ីណានោះទេ ។ គ្រាន់តែចុចប៉ាច់ក្តឹងទៅបាត់ហើយ ។ លេវិវចិនដូចគ្នា មិនប្រើខ្សែភ្លើងទេ វាប្រើអាខ្សែចរន្តហ្នឹងតែម្តង អាខ្សែហ្នឹងដាក់បាញ់ ដូចបាញ់ខ្សែហ្នឹង ចូលទៅក្នុងខ្សែនេះតែម្តង ។

បូលីៈ ពូមានដឹងថានៅលើ១០០១ហ្នឹង មានប៉ុន្មានកងពលទេ ក្រៅពី៨០១ មានកងពលអីខ្លះ អីផ្សេងទៀត?

យានៈ មើលតាមខ្ញុំដឹងមានតែ ៩២០ កងពល៨០១ ។ កាលហ្នឹងវាមានកងពល ខ្ញុំដឹងតែធ្វើការជាមួយគ្នា មានតែ៩២០ បាទ! ហើយហ្នឹង៨០១ ព្រោះគេថា១០០១ហ្នឹង វានៅបានកងពលហើយចឹងវាមាននៅ១០០២,១០០៣ទៀតនែក៉ ខាងនេះទៀត មកខាងលិចទៀត ។

បូលី៖ ពូនៅតែ១០០១នេះទេ?

យ៉ាន៖ ហ្នឹងហើយ១០០១តែឯង ដល់យើងឆ្នាំ៨៤ បានយួនវាយចូលទន្លេល្ពៅ បានខ្ញុំរត់នោះ ខ្ញុំនៅក្នុងនោះ នៅទន្លេសាប ពួកខ្ញុំនៅទន្លេសាប អាហ្នឹងពួកខ្ញុំចូលទន្លេសាប ។

បូលី៖ ពូទៅដល់ទន្លេសាបហើយ?

យ៉ាន៖ ទៅដល់ទន្លេសាបហើយ ។

បូលី៖ អ៊ីចឹងបានន័យថាពូមិនមែនធ្វើការតែនៅផែបទេនោះ?

យ៉ាន៖ បាទ! ដល់ដកហ្នឹងរុលទៅក្នុងវិញហើយ ។

បូលី៖ ពេលដែលគេវាយបែក ១០០១ហ្នឹង យើងរុលកាន់ជ្រៅ?

យ៉ាន៖ ខ្ញុំនឹងហើយធ្លាក់កម្លាំងទៅនៅនោះ កម្លាំងទៅនៅទន្លេសាបបាត់ហើយ ។

បូលី៖ ទន្លេសាបអីពូ?

យ៉ាន៖ បាទ!

បូលី៖ ទៅខាងនេះទន្លេសាប?

យ៉ាន៖ បាទ! កាលមុនខ្ញុំនៅព្រៃឡង់នែក ខ្ញុំនៅដែលវាយទន្លេល្ពៅណា ខ្ញុំនៅព្រៃឡង់ ដល់ចឹងបានឡានគេហៅទៅទន្លេសាប ហៅចុះកម្លាំងទាំងអស់ទន្លេសាប ។

បូលី៖ ពេលដែលទៅហ្នឹង កំពុងតែវាយ១០០១ ឬក៏បែកហើយបានទៅតាមក្រោយ?

យ៉ាន៖ ដឹងដំណឹងវាយបែកហើយបានទៅ ។

បូលី៖ យើងដឹងថាបែកហើយណ៎?

យ៉ាន៖ បាទៗ!

បូលី៖ បែកហើយយើងកាន់តែចូលជ្រៅតែម្តង?

យ៉ាន៖ ហ្នឹងហើយទៅក្នុងវិញ ។

បូលី៖ ដែលគេហៅចាក់សំបុកអន្ទ្រង់អីហ្នឹង?

យ៉ាន៖ បាទ!

បូលី៖ ឲ្យវាបែកខ្ទេកចឹងតែម្តង?

យ៉ាន៖ វាយស្កាត់ក្នុងៗវិញ ។

បូលី៖ ខាងយួនគេថា ដាក់មុខវាយមុខ បើខាងខ្មែរគេថាចាក់សំបុកអន្ទ្រង់ឆ្ងាយ ។ ចឹងបានន័យដំបូងយើងធ្វើការរាក់ៗទេ ដល់ពេលគេវាយបែក១០០១ អាកម្លាំងគេកាន់តែចូលកាន់តែជ្រៅ ។

យ៉ាន៖ នៅក្នុងនោះ ។

បូលី៖ នៅក្នុង!

យាន៖ បាទ! ខ្ញុំគិតទៅ ។

បូលី៖ ខ្ញុំណាមកទន្លេសាប?

យាន៖ ទន្លេសាបធ្វើនៅ ភ្លេចអស់ហើយនេះ នៅជិតជាប់ព្រំដែនគ្រោះថ្នាក់ ។

បូលី៖ ប៉ុនក្នុងខេត្តអី?

យាន៖ បាទ! នៅខេត្តកំពង់ធំ ។

បូលី៖ នៅក្នុងណា?

យាន៖ បាទ! ណោជាប់ព្រំប្រទល់កំពង់ឆ្នាំង ។

បូលី៖ អានេះកំពង់ធំណាពូ?

យាន៖ បាទ!

បូលី៖ អានេះកំពង់ឆ្នាំង ចឹងអានេះអាចអើ!

យាន៖ ខ្ញុំចឹងកំពង់រៀល ចឹងហ្ន៎ច្រើនណាស់ ។

បូលី៖ នៅគៀកទន្លេសាបគេម្ដង?

យាន៖ បាទ! គៀកទន្លេសាបហ្នឹង តាមព្រែទន្លេសាបហ្នឹងឯង ។

បូលី៖ ទន្លេសាបនេះពូនេះ?

យាន៖ បាទ! អូនឯងមើលទួលរូត មានទួលណា ។

បូលី៖ អានេះវាឲ្យត្រឹមស្រុកណាពូ ។ ពូចាំស្រុកទេ ស្រុកអីគេកំពង់ធំ?

យាន៖ នៅស្រុកបារាយណ៍ ។

បូលី៖ ហ្ន៎! នៅបារាយណ៍ហ៎?

យាន៖ បាទ!

បូលី៖ នៅបារាយណ៍បរិបូរ កំពង់ឆ្នាំង ។ នៅខ្ញុំនេះចឹង!

យាន៖ បាទ! ចឹងរៀល ចឹងអីហ្នឹងឯង ។

បូលី៖ បាទ!

យាន៖ បាទ! ខ្ញុំហ្នឹង ។

បូលី៖ អីចឹងបានន័យថា អ្នក១០០១នេះ ក៏ចូលមកកំពង់ធំ កំពង់ឆ្នាំងនេះដែរ?

យាន៖ បាទ!

បូលី៖ ក្រោយ៨៤, ៨៥ហ៎?

យាន៖ បាទ!

បូលី៖ មុនដំបូងនៅព្រះវិហារសិន?

យាន៖ នៅព្រះវិហារសិន ដូចស្ពានកណ្តាលចឹងខ្ញុំ នៅមួយក្រុមណា ខ្ញុំធ្វើការនៅព្រៃឡង់ ។

បូលី៖ ហើយពូធ្វើដំណើរមកយ៉ាងម៉េច ពីនែបមកដល់កំពង់ធំហ្នឹង?

យាន៖ ដើរ!

បូលី៖ ដើរកាត់ហ្នឹងរហូត?

យាន៖ បាទ! ដើរកាត់រហូត ។

បូលី៖ កាត់ព្រៃ?

យាន៖ កាត់ព្រៃ!

បូលី៖ មានកាត់ភូមិប្រជាជនទេ?

យាន៖ អត់ទេ! ទាល់តែប្រជាជន ទាល់តែអត់មានកម្លាំងកន្លែងហ្នឹង ដូចថាសមរភូមិប្រទាញប្រទង់អី ហ្នឹងណា ដល់យួនចូល បាទ! យើងមករកស្កាត់រកអង្ករកអី ។

បូលី៖ ពេលដើរមកមានប្រទះឃើញមានកងទ័ពយួន កងទ័ពរដ្ឋាភិបាលទេ?

យាន៖ អត់បានជួបទេ អន្ទុយក្នុងព្រៃ ។

បូលី៖ ហេងដែលចឹង ។

យាន៖ ចុះយើងដើរជាក្រុម គ្នាតិច មកឆ្លងថ្នល់ជាតិលេខ៦ទៀត ។

បូលី៖ ពូដឹងថា៨០ ១ហ្នឹង កាលពេលដែលវៀតណាមវាយមិនទាន់បែក ក្រៅពីធ្វើការនៅព្រះវិហារ ចុះមកធ្វើការនៅខេត្តណាទៀត, ៨០ ១ណា?

យាន៖ ដូចខ្ញុំថាចឹង នៅជុំវិញទន្លេសាបសិន អត់ទាន់បែកគ្នាទេ នៅជុំទន្លេសាបនេះឯង ។

បូលី៖ មុន៨៤, ៨២ ទៅ៨៣អីណា?

យាន៖ ហ្នឹងហើយ! កម្លាំងហ្នឹង មកនៅកំពង់ធំ កម្លាំងមួយចំនួនតូចៗ គេចូលដល់កំពង់ចាមនោះ ៨២ ទៅ៨៣ហ្នឹងហើយ វាកម្លាំងមកនៅកំពង់ធំ នៅកម្លាំងមួយចំនួនតូចៗ គេចូលដល់កំពង់ចាម!

បូលី៖ ហ៊ូ ចូលដល់កំពង់ចាមនេះពូ?

យាន៖ បាទ! នៅម្តុំចម្ការលើនោះ នៅម្តុំទឹកឆាអីហ្នឹង ។

បូលី៖ ទឹកឆាៗ!

យាន៖ បាទ!

បូលី៖ នេះ ទឹកឆា ចម្ការលើម្តុំនេះ ។ នេះខ្ញុំបាញ់ព្រួញមកដល់កំពង់ចាមនេះ យើងវាមិនអាចលម្អិតថាមកដល់ទីតាំងណាប៉ុន្មានទេ ព្រោះវាច្រើនណាពូ វារាប់ពាន់កងចុះមក ។

យាន៖ ហ៊ូច្រើនណាស់ ។

បូលីៈ ចឹងយើងអាចដៅបានតែធំៗទេ ហើយពេលនាបានពូឡើងពីទន្លេសាប ហើយបកទៅលើវិញ?
យានៈ ទាល់តែ នេះយើងអត់បានឡើងមកទេ តាមនេះវិញ ។
បូលីៈ មក១០០៣?
យានៈ បាទ! ១០០៣វិញ ។ មីង គេដឹកចេញពីនេះ មក១០០៣វិញ ។ ម្តុំនៅត្រង់ណាទេ ប៉ុនខ្ញុំ តាមនេះឯង ម្តុំយើងគេហៅក្នុងនេះនៅជាំស្វា ។
បូលីៈ ជាំស្វា?
យានៈ បាទ! ជាំស្វា ពង្រាយរហូតដល់ គ-៧ អូរគ្រាវ ។
បូលីៈ មុនដំបូងជាំស្វាសិន?
យានៈ បាទ! ជាំស្វាមានតាមកម្លាំងទៀត តាមកម្លាំងណា ។
បូលីៈ ពីកើតទៅលិច?
យានៈ បាទ! ទៅលិចរហូត ។
បូលីៈ វាយទៅលិចរហូត! ពីដំបូងទៅជាំស្វាណ៎ពូ?
យានៈ បាទ! ជាំស្វា ។
បូលីៈ ហើយបន្ទាប់មកគ-៧?
យានៈ គ-៧ ។
បូលីៈ ស្អីគេគ-៧?
យានៈ ធ្វើម៉េចពាក្យគេហៅគ-៧ ។
បូលីៈ គ-៧ ក្រែងមន្ទីរ របស់គាណាៗ?
យានៈ ហ្នឹងហើយ បានគេហៅគ-៧ៗហ្នឹង ។
បូលីៈ ផុតពីគ-៧ បានៗ?
យានៈ អូរគ្រាវ បាទ! ចង់អន្លុរ អូរគ្រាវ ។
បូលីៈ ចុះជប់ម្ល?
យានៈ ជប់ម្ល! អាហ្នឹងទៅ៨០៣ ទៀត ។
បូលីៈ ទៅលិចទៀត?
យានៈ ទៅឯលិចទៀត ។
បូលីៈ អូរគ្រាវទៀត?
យានៈ ហ្នឹងហើយអូរគ្រាវទៀត ។ ស្រែព្រៃ បានជប់ម្ល បាន៨០៨ ។
បូលីៈ ពូ! សូមជួយរាប់ម្តងទៀត មុនដំបូងជាំស្វា!

យាន៖ ដាំស្វា! ដាំស្វា ហើយក-៧, ក-៧ ហើយអូរគ្រាវ, អូរគ្រាវហើយនែ៎ក ស្រែព្រៃ, ស្រែព្រៃហើយដប់មួ, ដប់មួហើយបាន៨០៨, បាទ! ខ្ញុំស្គាល់តែត្រឹមហ្នឹងទេ ។

បូលី៖ ទាំងអស់ហ្នឹងនៅក្នុងដីថៃ ឬក៏ដីខ្មែរ?

យាន៖ សុទ្ធតែដី យើងនៅជិតដីថៃ ។

បូលី៖ ដីថៃ?

យាន៖ បាទ!

បូលី៖ ៨០៨ ក្រែងនៅដីខ្មែរពូ?

យាន៖ ៨០៨?

បូលី៖ បាទ!

យាន៖ ដឹងយ៉ាងម៉េច ប៉ុនខ្ញុំគ្រាន់តែឃើញអូរគ្រាវនោះ គេថាឲ្យតែតាម៉ុកធ្វើផ្ទះថ្មកន្លែងនោះដីខ្មែរត្រង់ហ្នឹង ។

បូលី៖ គេនិយាយចឹងតែម្ដង?

យាន៖ គេនិយាយចឹងណា!

បូលី៖ តាម៉ុកធ្វើផ្ទះថ្មកន្លែងណា ដីខ្មែរត្រឹមហ្នឹង?

យាន៖ បាទ! ដីខ្មែរត្រឹមហ្នឹង ។

បូលី៖ ប៉ុនខ្ញុំចង់ដឹងពេលដែលពូចេញពីនែបមកនៅម៉ុំបឹងទន្លេសាបពូ ពេលហ្នឹងពូមិនត្រលប់ទៅ ១០០៣ មែនទេពូ, ពូដើរតាមត្រឡោះណាទៅ១០០៣?

យាន៖ ១០០៣ ខ្ញុំឡើងតាមព្រៃស្អាកនេះឯង ។

បូលី៖ ឧទាហរណ៍ ប៉ុនពូនៅបារាយណ៍ណា បារាយណ៍នៅម៉ុំនេះ មិនចឹងទេពូ?

យាន៖ បាទ!

បូលី៖ ពូដើរយ៉ាងម៉េច ខ្ញុំឆ្ងល់?

យាន៖ បារាយណ៍ ខ្ញុំកាត់មកលើ ។

បូលី៖ ពូដើរទៅចេះ?

យាន៖ យើងឆ្លងមកចូលកមពង់ធំវិញ មកម៉ុំនេះម៉ុំសន្ទុកវិញ ។

បូលី៖ ម៉ុំសន្ទុក?

យាន៖ បាទ!

បូលី៖ នេះពូដើរចេញពីនេះមកនេះ មកសន្ទុក ។

យាន៖ មកសន្ទុក!

បូលីៈ  បន្ទាប់ពីហ្នឹង មកណាទៀត?

យានៈ  សន្ទុកមកបានយើង ឆ្លងកាត់មកស្រុកស្ទោង។

បូលីៈ  ស្រុកស្ទោងនេះពូនេះ?

យានៈ  បាទ! វានៅម្តុំស្ទឹ គេហៅវិហារជង់ក្តារនេះណា អាវិហារសគ្រាម កាត់អាហ្នឹង។

បូលីៈ  វិហារសគ្រាម! បន្ទាប់មក?

យានៈ  មានចេញមកឯនេះមក មិនដឹងឯណាទៀត។

បូលីៈ  សៀមរាប ឬក៏ព្រះវិហារ?

យានៈ  នៅដីសៀមរាបដែរ។

បូលីៈ  នេះស្ទោង អានេះ១០០៣។ ផ្លូវពូចាប់ពីស្ទោងមក១០០៣ ពូចាក់តាមណា?

យានៈ  អានេះស្ទោង បានន័យខ្ញុំថាកែក អំបាញ់មិញហ្នឹង!

បូលីៈ  វិហារសគ្រាម?

យានៈ  បាទ! វិហារសគ្រាមហ្នឹងណាំ។ អានេះវិហារសគ្រាមមកកាត់ មកនែកអូរទំនប់(ស្តាប់ពុំបាន) ភ្នំពេញនេះ។

បូលីៈ  អីចឹង មានតែកាត់តាមខេត្តសៀមរាប?

យានៈ  ហ្នឹងហើយ កាត់តាមសៀមរាបហ្នឹង ស្វាយលើ។

បូលីៈ  ឡើងទៅ១០០៣វិញ?

យានៈ  បាទ!

បូលីៈ  អានេះស្វាយលើ?

យានៈ  ស្វាយលើចូលព្រៃស្អាក។

បូលីៈ  ស្វាយលើហើយ ចូលព្រៃស្អាក ព្រៃស្អាកហើយ ចូលឧត្តរមានជ័យហើយ?

យានៈ  បាទ!

បូលីៈ  ហើយព្រៃស្អាកហើយ?

យានៈ  ចាក់មកឡើងមក។ អានេះគេហៅកន្ទែង គេហៅថាវាលមរណៈ។

បូលីៈ  វាមរណៈ?

យានៈ  បាទ!

បូលីៈ  យ៉ាងម៉េច បានហៅវាលមរណៈ?

យានៈ  ហៅវាលមរណៈ ពេលចុះមកផុតពីអាហ្នឹង ដឹងតែរស់ហើយ ផុតពីជម្ងោះណាអូន។

បូលីៈ  ផុតពីវាលហ្នឹង គឺរស់ហើយ?

យាន៖ បាទ! ផុតពីវាល អាជម្នោះហ្នឹង ដែលយួនវាកាប់ដាក់មីនណា! ផុតពីហ្នឹងរស់ បើចេះឡើង ឡើងមកចេះផុតពីហ្នឹង បានរស់ គេហៅវាលមរណៈហើយចឹង ។

បូលី៖ ខ្ញុំចង់សុំសួរពូតិចទៀត អានេះទាក់ទងស្រុកអន្លង់វែងណាពូ?

យាន៖ បាទ!

បូលី៖ នេះព្រំប្រទល់វា ស្រុកអន្លង់វែង អានេះត្រពាំងតាយណាពូ?

យាន៖ បាទ!

បូលី៖ អានេះត្រឹមនេះ មកដល់ត្រឹមនេះអន្លង់វែង ។

យាន៖ អន្លង់វែង ត្រូវហើយ ។

បូលី៖ អានេះត្រពាំងប្រាសាទណាពូណ៎?

យាន៖ បាទ!

បូលី៖ អំបាញ់មិញពូមានប្រសាសន៍ថា តំបន់១០០៣ហ្នឹង ទាំងអូរហ្នឹង វា១០០៣ ណាពូណា ភ្នំ១០០៣ ហើយនេះ តាម៉ុកគាត់គ្រប់គ្រង ។ ១០០៣ មុនដំបូង គឺជាំស្លាណ៎ពូណ៎?

យាន៖ បាទ!

បូលី៖ ជាំស្លា នៅម្តុំណាពូ? អានេះអូរស្មាយ អានេះព្រះប្រលាយ ។

យាន៖ នេះម្តុំអីគេហៅវាល វាលលា វាអីនេះ ។

បូលី៖ ចាំមើល ខ្ញុំអានឲ្យពូស្តាប់! មានអូរបេងណ៎ពូណ៎ វាមានប្រទាល មានបន្ទាយមាស ។

យាន៖ នេះក្នុងដីយើង អានេះដីយើងហើយ ។ អានេះក្នុងដីថៃ ប៉ុនជាំស្លា ទល់មុខនេះឃុនហាននេះ ។

បូលី៖ បើយើងគិតពីដីខ្មែរវិញ តើវាទល់មុខអី ទល់មុខព្រះប្រលាយទេ ឬក៏អូរស្មាយ?

យាន៖ ទល់ចំអូរស្មាយ ។

បូលី៖ ទល់អូរស្មាយវិញចឹងហ៎?

យាន៖ ហ្នឹងហើយ គេហៅច្រកដំរីគាប ។ ដំរីគាបនេះវានៅពាក់កណ្តាល ។ អាដំរីគាបហ្នឹងណា?

បូលី៖ បាទ!

យាន៖ ច្រកកោងហ្នឹងណ៎!

បូលី៖ បាទ!

យាន៖ ពាក់កណ្តាល ក-៧ ពាក់កណ្តាល ជាំស្លា អាដំរីគាបនេះ ។

បូលី៖ ចុះឈូករុន ហើយហ្នឹងចាំស្លាខុសគ្នាយ៉ាងម៉េច?

យាន៖ បើថាក្បាលហុង ហុងហើយនេះ អាហ្នឹងបានចំជាំស្លា ។ ខ្ញុំឡើងចំអាក្បាលហុងនេះឯង បាទ! ជាន់មីនស្លាប់អស់៤នាក់ ។

បូលី៖ កន្លែងនេះអត់ដាក់ឲ្យយើងដឹងជាំស្វា ជាំអីហ្នឹង អត់មានទេ ។

យាន៖ ប៉ុនខ្ញុំដឹងថាបើដីរ ស្របកកោង ដីរតាមហ្នឹង ពាក់កណ្ដាលហើយ ពាក់កណ្ដាលអូរអំពិល ពាក់កណ្ដាលជាំស្វា ។

បូលី៖ ចុះបើយើងឡើងពីទំនប់ជាច់ ពីលើផ្លូវនេះទៅណាពូ ឡើងទៅតាមប្រកឈូករុន?

យាន៖ អាហ្នឹងគេហៅ ជិតដែរ ជិតជាំស្វាដែរ ។ គេហៅវាលលា ចេញពីចម្ការម្ទេសនោះ វាលលា ។

បូលី៖ ចម្ការម្ទេសនៅក្នុងឃុំអី?

យាន៖ នៅចម្ការម្ទេសហ្នឹង វានៅព្រំប្រទល់ដីថៃ ដីខ្មែរ ។

បូលី៖ អាព្រំប្រទល់វាមានអូរស្មាយ វាមានព្រះប្រលាយ ។

យាន៖ នៅនេះ!

បូលី៖ ព្រះប្រលាយ?

យាន៖ បាទ!

បូលី៖ ចឹងបានន័យថាឈូករុននេះ នៅជាំក្សាន្ត នៅទល់មុខព្រះប្រលាយ?

យាន៖ បាទ!

បូលី៖ អាចថានៅម្ដុំនេះពូ?

យាន៖ បាទ! ហ្នឹងហើយអានៅទល់ហ្នឹងព្រះប្រលាយនេះឯង ។

បូលី៖ នេះអាចថានៅជាំស្វាណ៎ាពូ?

យាន៖ បាទ! ១ជួរឈូករុន ។

បូលី៖ ពូអាជួយពន្យល់ ខ្ញុំគិតបានទេ ជាំស្វា និងឈូករុនខុសគ្នាបែបម៉េច?

យាន៖ អានេះវាដីថៃ អានេះវាដីខ្មែរយើង ព្រំប្រទល់ខ្មែរ ។

បូលី៖ ឈូករុននៅជាប្រកព្រំដែនដីខ្មែរ ជាំស្វាជាជំរុំក្នុងដីថៃ ។ ចឹងបើសិនជាជាំស្វានៅម្ដុំនេះ ទល់មុខព្រះប្រលាយ ឈូករុនអាចនៅម្ដុំនេះបានទេ?

យាន៖ បាទ! វាឆាកនៅឆាកហ្នឹងឯង ។

បូលី៖ អាចចឹងណាពូ?

យាន៖ បាទ! ឆាកចឹងឯង ។

បូលី៖ ឈូករុន ។

យាន៖ ព្រោះអី ខ្ញុំនៅក្រោយឃុនហាន ជាំសាលាហ្នឹងណា!

បូលី៖ បាទ! ឃុនហានហ្នឹង ស្រុករបស់ថៃហ៎?

យាន៖ បាទ!

បូលី៖ នៅក្នុងខេត្តអីគេ?

យាន៖ ហ្នឹងខេត្តស៊ីសាកេត!

បូលី៖ ស៊ីសាកេតហើយណ៎?

យាន៖ បាទ!

បូលី៖ ផាកពីជាំស្វាមកលិច អីទៀតពូថាមិញ?

យាន៖ គ-៧ ។

បូលី៖ គ-៧?

យាន៖ បាទ! គ្រាន់តែខ្ញុំដឹងថា គ-៧ ប៉ុន្តែកន្លែងណានៅណាៗ មិនដឹងទេណា ។ គ-៧ ហើយបាន ចង់ក, ចង់កហើយបាន អូរគ្រាវ ។

បូលី៖ បើអូរគ្រាវ មកទល់មុខអន្លង់វែងវិញហើយនែក?

យាន៖ បាទ! អូរគ្រាវ ។

បូលី៖ ប៉ុន្តែគ-៧ ហើយចង់ក នៅត្រពាំងប្រាសាទ ឬក៏?

យាន៖ អត់ទេ! ទល់មុខអន្លង់វែងនេះទេ អូរគ្រាវ ជាប់អូរស្មាយហ្នឹងឯង ។

បូលី៖ នេះអូរស្មាយ ណ៎ពូណ៎?

យាន៖ ខ្ញុំឡើងជណ្ដើរ៨ នេះខ្ញុំឡើងទៅយកកូនខ្ញុំណ៎ ។

បូលី៖ ចឹងអានេះ អាចថាអូរគ្រាវនៅគម្លាតនេះទេណ៎?

យាន៖ បាទ! ខ្ញុំឡើងចំអាជណ្ដើរ៨ ។

បូលី៖ អីគេជណ្ដើរ៨?

យាន៖ អេ៎ ជណ្ដើរ៩០ ។ ឡើងជណ្ដើរ៩០ ។

បូលី៖ ប្រក៩០?

យាន៖ បាទ! ប្រកជណ្ដើរ៩០ ខ្ញុំឡើងជាមួយតាម៉ុន ។

បូលី៖ អូរគ្រាវនេះ ទល់មុខអូរស្មាយទេចឹងណ៎?

យាន៖ បាទ! ទល់មុខអូរស្មាយ ព្រោះអីខ្ញុំឡើងទៅ ខ្ញុំដេកផ្ទះមេឃុំអីលើហ្នឹង បងសឿងហ្នឹង ទៅលេងផ្ទះគាត់ ខ្ញុំឡើងទៅអូរគ្រាវហ្នឹងទៅលេងផ្ទះគាត់ ។

បូលី៖ ចុះមិញពូថា ចង់ក ណ៎?

យាន៖ បាទ! ចង់ក ។

បូលី៖ នៅចន្លោះនេះណ៎?

យាន៖ ហ្នឹងហើយចន្លោះ ។

បូលីៈ   អាចថាគ-៧  នេះចឹងទៅ  ចងក  នៅនេះ ។

ដានីៈ   ចុះស៊ីងចាន់នៅឯណា?

យានៈ  ស៊ីងចាន់នៅក្រោយគ្នា  នៅពីក្រោយគ-៧នេះទៀត ។

បូលីៈ   ឧទាហរណ៍សិនណាពូណា  ឧទាហរណ៍ថាអានេះគ-៧  គេហៅគ-៧ចឹងតែម្ដង?

យានៈ  គ-៧ ។  ព្រោះជិតដែរ  នៅចងក  និងអូរគ្រាវនេះ ។

អ្នកជិតខាងៈ  ក្រែង  គ-៧  ហ្នឹង  អូរគ្រាវអី?

យានៈ  គ-៧  ហើយចងក, ចងកហើយ  បានអូរគ្រាវ ។

អ្នកជិតខាងៈ  ចឹង?

យានៈ  ហ៉ើយ៉ាងម៉េចបង! ចងកហើយអូរគ្រាវ  អូរគ្រាវហើយបានយើងចេញទៅន៉ែកស្រែព្រៃ,

ស្រែព្រៃហើយបាន ជប់ម្ជូ, ជប់ម្ជូហើយបាន៨០៨ ។

បូលីៈ   ឥលូវជប់ម្ជូនៅខាងណាអូរគ្រាវពូ?

យានៈ  ជប់ម្ជូវានៅខាង  ចាំមើលខ្ញុំរត់មក  មកពីស្រែព្រៃ  នៅខាងនេះអូរគ្រាវ  នៅខាងលិចទៀត ។

អ្នកជិតខាងៈ  នៅខាងលិចអូរគ្រាវទៀត  ជប់ម្ជូ ។

យានៈ  ជប់ម្ជូ  បាទ!  ជិតដាំ  អាហ្នឹងបានចូលជិតថៃ ។

បូលីៈ   អាចត្រូវ  ព្រោះថាតាម៉ុក  ពេលគាត់ធ្វើផ្លូវចុះមកពីស្រុកដាំហ្នឹង  គឺភ្ជាប់ទៅជប់ម្ជូហើយ?

យានៈ  បាទ!  កន្លែងគាត់ដាំម្នាស់អី  កន្លែងភ្នំនោះគាត់ដាំម្នាស់  ជប់ម្ជូហើយ  គាត់ដាំ  កំពុងដាំ  ម្នាស់

ដឹកសុទ្ធតែ(ស្ដាប់ពុំបាន) ។

បូលីៈ   ជប់ម្ជូ!  ចឹងបានន័យថានេះ  អាហ្នឹងព្រំដែនត្រពាំងប្រាសាទ  ចេញពីត្រពាំងប្រាសាទនេះមក

អន្លង់វែង  ច្រកដាំនៅម្ដុំនេះលោកពូ ។

យានៈ  ហ្នឹងហើយច្រកដាំនៅជប់ម្ជូជិតគ្នាតា ។

បូលីៈ   ច្រកដាំស្រះឈូក ។

អ្នកជិតខាងៈ  ហើយបាន៨០៨  បានស្រែព្រៃ ។

បូលីៈ   ជប់ម្ជូអាចថានៅម្ដុំនេះដែរទេ?

យានៈ  ហ្នឹងហើយក្នុងដីថៃ ។

បូលីៈ   ជប់ម្ជូ  ដីថៃ ។  ប៉ុន្ដជប់ម្ជូ  ទល់មុខច្រកដាំទេ?

យានៈ  ជិតច្រកដាំហ្នឹងឯង ។

បូលីៈ   អាចជប់ម្ជូនៅត្រង់នេះណ៎ពូណ៎ ។  អំបាញ់មិញ  ពូធាស្រែព្រៃមួយទៀត?

យានៈ  ស្រែព្រៃ ។

បូលី៖ ខាងលិចជប់មួ ឬខាងកើត?

យាន៖ ទៅឯលិចទៀត។

បូលី៖ មកខាងអូរអង្គ្រែវិញចឹង ហើយឬក៏យ៉ាងម៉េច?

យាន៖ វាខ្ពាត ដល់ហ្នឹង។

ដានី៖ អូរអង្គ្រែ ៨០៨!

យាន៖ បាទ! ហ្នឹងហើយជប់មួ ត្រពាំងព្រៃហ្នឹងហើយ ៨០៨។

បូលី៖ នេះត្រពាំងតាវណាស់ គេហៅត្រពាំងព្រៃៗ ហ្នឹងដីថៃទេណា។

ដានី៖ ត្រពាំងព្រៃមួយ ត្រពាំងព្រៃរបស់!

យាន៖ អានេះត្រពាំងព្រៃនេះ។

ដានី៖ អានេះផ្សេងទេណ៎?

យាន៖ ត្រពាំងព្រៃនៅក្នុងដីថៃ ភូមិត្រពាំងព្រៃថៃៗ។

អ្នកជិតខាង៖ ស្រែព្រៃទេអី?

យាន៖ អើហ្នឹងហើយ! ត្រពាំងព្រៃអី ស្រែព្រៃ។

បូលី៖ ស្រែព្រៃហ្នឹងពូ?

យាន៖ ស្រែព្រៃ។

បូលី៖ ចឹងស្រែព្រៃហ្នឹង នៅខាងលិចជប់មួទៀត?

យាន៖ ជប់មួ។

បូលី៖ នៅទល់មុខអីពូ នៅទល់មុខឃុំត្រពាំងតាវទេ?

យាន៖ អាចចូលអាហ្នឹងឯង។

បូលី៖ ទល់មុខឃុំត្រពាំងតាច។

យាន៖ ហ្នឹងហើយ! ទល់មុខត្រពាំងតាវហ្នឹងហើយ។

បូលី៖ អានេះៗ ត្រពាំងតាវ។ អានេះត្រពាំងព្រៃ អាត្រឹមនេះមកត្រពាំងព្រៃណ៎ពូណ៎។ អានេះ ចន្លោះនេះ អន្លង់វែង, ចន្លោះនេះ ឃុំត្រពាំងតាវ អីចឹងស្រែព្រៃហ្នឹងនៅទល់មុខត្រពាំងតាវ។ នៅកាត់មុំនេះដីថៃហ៎ក ពូ?

យាន៖ ដីថៃ!

បូលី៖ ដីថៃ! ហេតុអ្វីបានឈ្មោះស្រែព្រៃ ដូចខ្មែរអីចឹង?

យាន៖ ឈ្មោះភូមិស្រែព្រៃចឹងតែម្តង។ បាទ! ស្រែព្រៃហើយ បានទៅ៨០៨តែម្តង។

ដានី៖ ៨០៨ ទល់មុខនឹងស្ទឹរបស់ខ្មែរយើង។

យាន៖ ដូចជាចំស្អីទេ! ខ្ញុំចុះមកចំ មកតាមហ្នឹងដែរ មិនដឹងចំស្អីទេ។

បូលី៖ ៨០៨ ក្នុងដីខ្មែរ ឬក្នុងដីថៃ?

យាន៖ ៨០៨ហ្នឹង ដីថៃ ដីខ្មែរហ្នឹង។

បូលី៖ មុនពេលវាយយកបានហ៎?

យាន៖ បាទ!

បូលី៖ គេហៅអាកន្លែងសមុទ្រ ដែលខាងកម្លាំងខ្មែរក្រហមវាយជាមួយយួនណ៎?

យាន៖ បាទៗ! ៨០៨។

បូលី៖ ព្រោះអីចង់ដឹងទីតាំង យើងស្រួលគូរដែនទី។

ដានី៖ ត្រពាំងតាវ, តាដេវ ហើយ៨០៨ មកទល់ជាមួយស្អីទៅ? ភូមិអូរអង្ក្រែ នៅផ្ទះរបស់?

យាន៖ នៅលើ។

ដានី៖ អត់ដែលទៅដល់! ចុះបើខាងនេះវិញ?

យាន៖ ធ្លាប់យកតែដីក ទៅដាក់ខ្ញុំនៅហ្នឹងឯង។

បូលី៖ ជប់មួនៅទាល់មុខដាំ!

យាន៖ បាទ!

បូលី៖ ឈូករុននៅជាំស្លានេះទេ ណ៎ពូណ៎?

យាន៖ បាទ!

បូលី៖ ឈូករុននៅព្រំដែនណ៎ពូណ៎?

យាន៖ បាទ!

បូលី៖ អានេះឈូករុន។

យាន៖ កាលតាម៉ុកនោះ នៅត្រពាំងព្រៃ នៅចម្ការម្មេសនោះ។

ដានី៖ នៅចម្ការម្មេសនៅហួស នៅម្តុំជាំស្លាហ្នឹង?

យាន៖ អាហ្នឹងចម្ការម្មេសហ្នឹងវាមិនទាន់ដល់ជាំស្លាទេ។

បូលី៖ នៅដីខ្មែរ ឬនៅដីថៃ ចម្ការម្មេសហ្នឹងពូ?

យាន៖ ចម្ការម្មេសហ្នឹងកាលមុន គឺនៅដីខ្មែរ។

បូលី៖ ដីខ្មែរទេណ៎?

យាន៖ អើ!

បូលី៖ ចឹងបានន័យថានៅក្រោមឈូករុនទេណ៎ពូណ៎?

យាន៖ បាទ!

បូលីៈ ទាល់តែចុះពីឈូករុនមក បានមកដល់ចម្ការម្ទេស ។ អាកន្លែងតាម៉ុកដាច់ជើងហ្នឹងហ៎?

យានៈ តាម៉ុកដាច់ជើង កន្លែងឈូករុនហ្នឹងឯង ។

បូលីៈ ពេលដែលគាត់ឈូសផ្លូវចុះមក?

យានៈ បាទ! ឈូសផ្លូវចុះមក ចុះមកព្រះប្រលាយហ្នឹង ។

បូលីៈ ព្រះប្រលាយហ្នឹង ដែលយើងចល័តកងទ័ពចូលមក គឺតាមឈូករុនហ្នឹងនែកពូណ៎?

យានៈ បាទ! ចុះមក និយាយរួមតាមផ្ទះខាងណាដែរ មុខសញ្ញាហ្នឹង ចុះត្រង់ហ្នឹងហើយ ។

អ្នកជិតខាងៈ ទីណាដែលលំបាកចុះត្រង់ហ្នឹង ខ្មែរក្រហម!

ដានីៈ តែចោតខ្លាំងចុះត្រង់ហ្នឹង ។

យានៈ ចុះបើវាកន្លែង ស្រួលមិនស្រួល យូននៅ ។

បូលីៈ ហ៎ូ! ចុះតាមវល្លិ៍តាមអីហ្នឹង ។

យានៈ តាមវល្លិ៍តាមអីហ្នឹង គេអ្នកចុះ ។

បូលីៈ ហើយយើងចុះពីហ្នឹងមក យើងចុះមកវាយនៅព្រៃស្អាងនេះ?

យានៈ គោលដៅនៅព្រៃស្អាក កន្លែងជុំវុំហើយអាហ្នឹង គោលដៅ ។

ដានីៈ ដងទង់អីនៅកន្លែងណាដងទង?

យានៈ បើដងទង់ដូចខ្ញុំថាអីចឹងនៅអាច្រក ចំច្រកនែ៎ក ដីរីគាប ស្របកកោងហ្នឹង កន្លែងហ្នឹងហៅដងទង់ ។ ចេញពីជាំស្វាមក មកដងទង់, ដងទង់ហ្នឹងបានមកនែ៎កគ-៧ ។

បូលីៈ ដងទង់ហើយបានគ-៧,ដងទង់ហើយ បានគ-៧ តាមក្រោយ?

យានៈ បាទ! មានដងទង់មួយទៀត ។

បូលីៈ ដងទង់នៅនេះ?

យានៈ ប៉ុន្តែ ខ្ញុំអត់មាន ស្គាល់ទេ ឮតែគេថាទេ មិនដឹងនៅម្តុំណាទេ ។ មីង១ដែលថាសម្រាលកូនអីនៅដងទង់ហ្នឹង ។

បូលីៈ ដងទង់នៅចន្លោះជាំក្សាន្ត នៅគ-៧ណ៎?

យានៈ បាទ១!

បូលីៈ បន្ទាប់មកចងករ, ចងក អូត្រាវ, អូត្រាវហើយបានដប់ម្ហូ ហើយស្រែព្រៃ ហើយបាន ៨០៨ ។

ដានីៈ ចឹង ៨០០?

យានៈ អត់ស្គាល់ទេ៨០០ ។ ស្គាល់តែ៨០៨!

បូលីៈ បើច្រក៩០ នៅឈូករុននេះវិញហ៎ពូ?

យាន៖  បាទ! ច្រក៥០ ។
បូលី៖  បើនៅ៥០ នៅខាងកើតនេះវិញទេអី?
យាន៖  អត់ទេ! នៅខាងលិចនេះវិញទេ មិនមែនកើតទេ។
បូលី៖  នៅចន្លោះណាវិញ?
យាន៖  នេះនៅម្ដុំនេះ!
អ្នកជិតខាង៖  ច្រក ៥០ នៅកើតនេះ។ នៅកើតឈូករន្ធ អានេះជណ្ដើរ៥០នៅលិច។
យាន៖  អានេះគេហៅអូរ៥០ ។ អាច្រកអូរ៥០ អាហ្នឹងនៅខាងនេះ។ ខ្ញុំទៅចាក់ជង្រុកជាមួយបង
អាហ្នឹងហើយ អូរ៥០ហ្នឹង គេហៅកញ្ជើរបង្អែរ។
បូលី៖  គេហៅអីឲ្យច្បាស់លាស់ ច្រកអូរ៥០ ឬក៏អូរ៥០?
យាន៖  អាហ្នឹងមួយគេហៅអូរ៥០ អានេះមួយជណ្ដើរ៥០ ។
បូលី៖  អូរមានពីរចឹង?
យាន៖  បាទ! មាន២ អាមួយអូរ៥០ អាមួយជណ្ដើរ៥០ ។
បូលី៖  អានេះជាច្រកមួយហ៎?
យាន៖  បាទ! អាហ្នឹងគ្រាន់តែជាកន្លែង។
បូលី៖  ឬក៏អូរ៥០ទេ?
យាន៖  អូរ៥០ៗចឹង! អត់មានច្រក គ្រាន់តែមានផ្លូវអូរ៥០ ខ្ញុំទៅដេកចាក់ចម្រូង។
បូលី៖  ចុះជណ្ដើរ៥០ នៅកន្លែងណា?
យាន៖  ជណ្ដើរ៥០ ដូចខ្ញុំថាអីចឹង ចន្លោះនែកជាំស្វា និងអូរត្រាវហ្នឹងឯង ព្រោះអីខ្ញុំឡើងទៅអីសាលា
៥០នឹងហើយ ឡើងទៅអូរត្រាវ។ ឡើងទៅចឹង ដើរទៅចេះវិញបានដល់អូរត្រាវវិញ។
បូលី៖  ជាំស្វា និងអូរត្រាវ?
យាន៖  បាទ!
បូលី៖  មកដល់គ-៧នៅ អា៥០ហ្នឹង?
យាន៖  អាហ្នឹង?
បូលី៖  បាទ!
យាន៖  អាហ្នឹងវានៅខាង វានៅជាមួយគ-៧ ចង្កក ហ្នឹងហើយវានៅចន្លោះ!
បូលី៖  ពូស្រម៉ៃមើល! ចន្លោះចង្កក និងគ-៧ ឬចន្លោះ ចង្កក និងអូរត្រាវ?
យាន៖  អាជណ្ដើរ៥០នោះវាឡើងតាមត្រពាំងចានដែក ខ្ញុំដើរកាត់នេះ ពីអូរបាក់រលួងនេះ ឡើង
តាមដានគោដឹក គេដឹកគោ។

បូលីៈ   នៅជណ្ដើរ៥០មួយទៀត យើងរកឃើញទេពូ?

យានៈ   អត់ឃើញខ្ញុំ ។

បូលីៈ   ហើយ៨០៨ នៅខាងលិចស្រែព្រៃហើយណ៎?

យានៈ   បាទ! ខាងលិចស្រែព្រៃទៀត ។

បូលីៈ   ចឹងវានៅទល់មុខត្រពាំងតាវ?

យានៈ   បាទ!

ដានីៈ   ទល់មុខអូរអង្រែ ឬក៏ត្រពាំងតាវ? បើនៅត្រពាំងតាវ វានៅឆ្ងាយ ។

យានៈ   វានៅចំៗ ឃុំត្រពាំងតាវហ្នឹងឯង ។ ដឹងមិនចំនរណាទេ គ្រាន់តែចំឃុំត្រពាំងតាវហ្នឹងហើយ ៨០៨ ។

អ្នកជិតខាងៈ អាហ្នឹងបានទៅសួរម្ដុំ ឃុំស្ពានដែក ។

យានៈ   ហ្នឹងហើយសួរពួកហ្នឹង បានដឹង ។

ដានីៈ   សួរយាយចែម?

យានៈ   សួរយាយចែម ។

ដានីៈ   ហើយចុះក្បាលទន្សោង នៅឯណាទៅក្បាលទន្សោង?

យានៈ   ក្បាលទន្សោងនៅចំកន្លែង ចំដាំស្រងាំហ្នឹងឯង ចំកន្លែងភូមិ!

ដានីៈ   ១០៥ ។

យានៈ   ហ្នឹងហើយភូមិ១០៥បានចំភូមិក្បាលទន្សោង ។

ដានីៈ   ១០៥ វាមិននៅក្នុងព្រំប្រទល់ជាមួយត្រពាំងប្រាសាទហើយណ៎ ក្នុងស្រុកភ្នំដ្អារ ១០៥ វាជាប់ព្រំប្រទល់ជាមួយអន្លង់វែង នៅខាងនេះបាត់ហើយចឹង?

យានៈ   បាទ! ហ្នឹងហើយនៅក្បាលទន្សោង ។

បូលីៈ   ចឹងក្បាលទន្សោងនៅក្នុងស្រុកត្រពាំងប្រាសាទ?

យានៈ   ស្រុកត្រពាំងប្រាសាទ នៅឃុំដ្អារ ។

បូលីៈ   នេះដ្អារ! អាចនេះមើលទៅ ។ អានេះព្រំប្រទល់ ខាងនេះអន្លង់វែង ខាងនេះត្រពាំងប្រាសាទ ។

ដានីៈ   ភូមិអីគេនេះ?

បូលីៈ   ឬស្សី ។

យានៈ   ឬស្សីដ្អារ នឹងឯង ។

បូលី៖ នេះប្រោកហ៎! ប្រោកនេះ៨០០ ឬក៏៤០? មានប្រេក៤០មួយទៀត។ ដែលពួទេប្រេក ៤០?

យាន៖ ប្រេក៤០?

បូលី៖ បាទ!

យាន៖ ប្រេក៤០ អីណាខ្ញុំភ្លេចហើយនេះ។

បូលី៖ វាចំនោមគ្នាជាមួយ៨០៨។

យាន៖ ហ្នឹងហើយវាទៅ ប្រេក៤០វាទៅឯលិចហ្នឹង។

បូលី៖ ម្ដុំប្រោក?

យាន៖ បាទ! ហ្នឹងឯង៤០ ធ្លាប់ឮប៉ុន្តែ ខ្ញុំអត់មែនអន្តភាពខ្ញុំ។

បូលី៖ ក្បាលទន្សោងអាចម្ដុំនេះហើយតាមមើលនែក៎?

យាន៖ ខ្ញុំមិនដឹង៤០ហ្នឹងនៅឯណា។

បូលី៖ នេះក្បាលទន្សោងបើនិយាយមែនទែនទៅ នៅក្នុងត្រពាំងប្រាសាទទេមែនណ៎?

យាន៖ ក្បាលទន្សោងនៅត្រពាំងប្រាសាទ១០០ភាគរយ។

បូលី៖ អាចនេះទេ តាមមើល?

យាន៖ ព្រំប្រទល់អន្លង់វែង និងត្រពាំងប្រាសាទនឹងឯង។

បូលី៖ ក្បាលទន្សោហ្នឹងពូ?

យាន៖ បាទ!

បូលី៖ ខ្ញុំដាក់នេះអីចេះចោះ! អាចថាខ្ញុំដាក់ចេះចោះ ខ្ញុំវាយស្មានសិនណាពូណា! តាមពិតយើង អត់ដឹងច្បាស់លាស់ម្ដុំណាទេក្បាលទន្សោង។ ក្បាលទន្សោងព្រំប្រទល់អន្លង់វែង និងត្រពាំងប្រាសាទ។

យាន៖ អាហ្នឹងកន្លែងប៉ុល ពតហើយហ្នឹង!

បូលី៖ ខៀវសំផន?

យាន៖ ថាផ្ទះគាត់ហើយហ្នឹង ខ្ញុំមិនដែលឃើញទេណ៎ ផ្ទះក្រោមដីផ្ទះអីនៅឯហ្នឹងឯង។

បូលី៖ ឥឡូវហ្នឹងមានផ្លូវចូលទៅដល់ទេ?

យាន៖ មានតាកន្លែងហ្នឹង គេទៅជាទេសចរណ៍ កន្លែងទេសចរណ៍។

បូលី៖ ប្រហែលជាមិនដែលទៅអត់ដល់ហ្នឹង។ មានអីទៀតប្រេកទៅក្នុងដី ដូចយើងហ្នឹង ចោះរណ្ដៅ? ឲ្យតែយើងដឹង(ស្ដាប់ពុំបាន) មិនចាំបាច់ដឹងច្បាស់លាស់កន្លែង ឲ្យតែដឹងថាអានេះមុន។

ដានី៖ ណាស៊ីនចាន់ម្ដុំណា?

យានៈ ស៊ីផចាន់ ខ្ញុំអត់ដែលទៅដល់ទេ ។

បូលីៈ ក្រែផនៅក្រោយអូរគ្រាវ?

យានៈ បាទ! ដីផតែពីក្រោយ! ប្រជាជនដែលថៃ មកធ្វើអី ខ្ញុំសួរណា ក៏ត្រូវឆ្លងស៊ីផចាន់មកអូរគ្រាវ ។

បូលីៈ ចឹងយើងអាចថានៅនេះ?

យានៈ នៅពីក្រោយ ព្រោះអីវានៅបណ្តោយតាមខ្សែស្របភ្នំ បាទនៅពីក្រោយស៊ីផចាន់ ព្រោះអីឪធម៌ខ្ញុំអីនៅ ឪធម៌ថៃអី សួរគាត់ថាអញ ផ្ទះអញនៅជាប់ស៊ីផចាន់ ។

ដានីៈ ហើយហ្វូណាយនៅឯណាហ្វូណាយ?

យានៈ ហ្វូណាយ?

បូលីៈ បាទ! ហ្វូណាយ ។

យានៈ ជិតហ្វូណាយ ជិតសាយធូរ ។ ហ្វូណាយអីនៅ លិចទៅទៀតនោះ ទៅនោះសុទ្ធតែជិតបារាំស់ ។

បូលីៈ ហ្វូណាយកាលរត់ទៅ៩៨ រដ្ឋាភិបាលគេវាយមក?

យានៈ ខ្ញុំមិនដែលស្គាល់ទេហ្វូណាយ ។

បូលីៈ នៅខាងតាជុំជាតិដែលកំពុងវាយ កំពុងរត់ឡើងហ្វូណាយ មួយជំនាន់៩៨នោះដែលយើងជិតសមាហរណកម្មហើយ ។

យានៈ ពួកខ្ញុំរត់មកនេះ ១ដុំមក ខ្ញុំមកនេះ ។

ដានីៈ ពូមកខាងទំនប់ដាច់?

យានៈ បាទ!

ដានីៈ ខាងពូដាន់ណា មកខាងអូរបាយតាប់ ។

យានៈ ហ្នឹងហើយទៅនោះ ។

ដានីៈ តាម៉ុក គាត់រត់ឡើងហ្វូណាយ ឡើងភ្នំ...

យានៈ ព្រោះខ្ញុំរវល់តែខ្លាចៗ ក្នុងឯងៗ ខ្លាចអាក្រក់ជាងយួនទៀតណា ។

បូលីៈ ចឹងហ៉ពូ?

យានៈ បាទ! ខ្លាចឯងហ្នឹងនេះ ព្រោះតាម៉ុកមកធ្វើការជល់គ្នា លែងញាក់ចឹងនោះបងនារី អន្ទុយញាក់ចឹងគេអត់ធ្វើអីទេ ប៉ុញាក់ចឹងតែម្តង ខ្ញុំខ្លាចគ្នាឯងអាក្រក់ណា ព្រោះខ្លាចក្រែងលោគេបាញ់ចោលនៅៗ(និយាយទូរស័ព្ទ) ។

បូលីៈ តាប៉ុល ពត គាត់មកអូរស្មាយនេះ?

យានៈ បាទ! មកអូរស្មាយនេះ ។

បូលីៈ គេដេញចាប់គាត់,

យានៈ ដេញចាប់!

បូលីៈ គាត់ចេញពីក្បាលទន្លេវាងមក ចាប់នៅអូរស្វាយមកពួននៅម្តុំនេះ?

យានៈ ហ្នឹងហើយ! ថៃ យន្តហោះខាងថៃនៅនេះ ។

បូលីៈ តាមពិត តាម៉ុកចាប់បាននៅម្តុំហ្នឹងតាចឹង?

យានៈ បាទ!

បូលីៈ ចាប់តាប៉ុល ពត?

យានៈ បាទ!

ដានីៈ ភ្នំអូរស្វាយ ។

យានៈ អត់ទេ! ចុះមកខ្លួនឯងតែម្តង ។

ដានីៈ មានរូងភ្នំ មានអីទេកន្លែងហ្នឹង?

យានៈ ដឹងយ៉ាងម៉េចទេ ខ្ញុំអត់ដែលស្គាល់ដែរ ។

ដានីៈ ចាប់នៅអូរស្វាយ!

យានៈ គាត់ចុះមក គេសែងចុះមក ។

បូលីៈ សែងចុះមកពីភ្នំមកវិញ?

យានៈ បាទ!

បូលីៈ កាលណាយើងឃើញអាអន្តាញ់ចេះ សុទ្ធតែភ្នំហើយនេះ?

យានៈ មិនមែនធម្មតាទេ ។

ដានីៈ ជាមួយឃុនណាល់ ជួនជឿន គេចុះមកកន្លែងហ្នឹងទាំងអស់?

យានៈ បាទ!

បូលីៈ ពូយល់ថា ជម្លោះជាមួយតាជួនជឿន ជាមួយតាប៉ុល ពតហ្នឹង នរណាត្រូវនរណាខុស?

យានៈ ព្រោះអី ខ្ញុំយល់ថា តាប៉ុល ពត គាត់ស្វែងរកសន្តិភាព គាត់ចង់ឲ្យកម្លាំងយើង គាត់ឃើញថា នៅ(ស្តាប់ពុំបាន) ឲ្យចូលមករដ្ឋាភិបាលមកដើម្បីរស់ ។ គាត់ប្រុងតែជួបគ្នាចរចាជាមួយ រដ្ឋាភិបាលនៅប្រាសាទព្រះវិហារ ។

បូលីៈ តាប៉ុល ពតហ្នឹង?

យានៈ បាទ!

បូលីៈ ក្រែងតាម៉ុកអី? តាម៉ុកនៅព្រះវិហា?

យានៈ អត់ទេ! តាម៉ុកគាត់ថាដាច់ក្បាលតក្បាល ដាច់កន្ទុយតកន្ទុយ ។

បូលី៖ ចឹងអ្នកដែលចរចានៅ ប្រាសាទព្រះវិហារហ្នឹង តាប៉ុល ពតទេមើលទៅ?

យាន៖ តាប៉ុល ពតទេ ។

បូលី៖ អ្នកឲ្យចរចាហ្នឹង?

យាន៖ បាទ!

បូលី៖ ដែលខៀវ សំផន, ទេព យុនណាទៅហ្នឹង?

យាន៖ បាទៗ!

បូលី៖ មិនមែនតាម៉ុកទេ?

យាន៖ មិនមែនតាម៉ុកទេ ។ ចឹងហើយបានតាម៉ុក គាត់ប្រឆាំងចាប់ផ្ដើមបែក តាម៉ុក ហើយតា ប៉ុល ពតបែកគ្នាឃើញទេ ។

បូលី៖ អានេះរឿងធំ បញ្ច្រាស់ទិសគ្នាទាំងស្រុង?

យាន៖ គាត់ថាដាច់ក្បាលតក្បាល ដាច់កន្ទុយតកន្ទុយ ។

បូលី៖ ពីរព្រោះម្នាងនិយាយថា តាម៉ុកទេអ្នកចរចានោះ តាមុតទេអ្នកជំទាស់ ។

យាន៖ អត់ទេ!

បូលី៖ ពូមានអីបង្ហាញដើម្បីជាភស្តុតាង ថាតាប៉ុលពតជាអ្នកផ្ដួចផ្ដើម ចរចាមិនមែនតាម៉ុក?

យាន៖ កម្លាំងដែលផ្ដួចផ្ដើម ឃើញតែកម្លាំងដែរពួកខ្ញុំចុះចូលជាមួយរដ្ឋាភិបាល ដូចបងដុំ បងអីហ្នឹង បងកែវ បងអីហ្នឹងឯង ។

បូលី៖ ជា កែវ?

យាន៖ បាទ! ជាកែវ ជាអីហ្នឹង ។ ហើយដែលតាម៉ុកចាប់យកសុទ្ធតែកម្លាំងប៉ុល ពតទាំងអស់ ។ ចាប់យកទៅដាក់នៅក្នុងគុក ។

បូលី៖ ចឹងតា០៥ គាត់ចង់ចរចាដែលអីចឹង?

យាន៖ បាទ! គាត់ហ្នឹងហើយប្រាប់កូនចៅ ដែលយើងដឹងណាតាម ខ្សែបន្ទៀវតាមរយៈមន្ទីរអីជីង ប្រាប់ពួកខ្ញុំថា រដ្ឋាភិបាលយើងចរចាហើយឆ្នាំ៩៨ហ្នឹងណា ។

បូលី៖ តាម៉ុក អត់ចង់ទេ?

យាន៖ អត់ចង់ទេ ។ បើតាម៉ុកចរចា មិនមែនតាម៉ុករត់គេចពីរដ្ឋាភិបាលយើង ដែលពួកកម្លាំងខ្ញុំ សារភាព ហើយ(ស្ដាប់ពុំបាន) ម៉េចកម្លាំងមួយចំនួនសារភាពមកចូលក្នុងរដ្ឋាភិបាលហើយ កម្លាំងគាត់រត់ទៅលើ ។

បូលី៖ បើតាមពូយល់ តាម៉ុកជាមនុស្សយ៉ាងម៉េចដែរ?

យាន៖ ថាមនុស្សយ៉ាងម៉េច គាត់ដឹកនាំ និយាយរួម កសិករ ចឹងធាតុគាត់ មិនមែនបញ្ញាជន មិនមែនអីទេ បញ្ញាវ័នអីទេ គាត់ដឹកនាំតាមកសិករ ។ អ្នកណារាយការណ៍មុនអ្នកហ្នឹងបានមុន ។

បូលី៖ ជម្លោះរវាងតាម៉ុក ហ្នឹងតាប៉ុល ពត គឺបង្ករឡើងអំពីអីទៅ?

យាន៖ ខ្ញុំអត់ដឹងបើនិយាយឲ្យខ្ញុំថាមកពី អាការចរចាជាមួយរដ្ឋាភិបាលហ្នឹងឯង បើតាមខ្ញុំយល់ណា មិនមែនជារឿងអីទេ គឺរឿងការមិនចុះសម្រុងគ្នាជាមួយរដ្ឋាភិបាលហ្នឹងឯង ។

បូលី៖ តាម៉ុក ហើយតាប៉ុល ពត ខ្វែងគំនិតគ្នា?

យាន៖ បាទ!

បូលី៖ តាប៉ុល ពតចង់ចរចា តាម៉ុកអត់ចង់ចរចា?

យាន៖ បាទ! ចុះបើឮតាម៉ុកថា ដាច់ក្បាលតក្បាល ដាច់កន្ទុយតកន្ទុយ គាត់ថាអីចឹង ។

ដានី៖ ពាក្យហ្នឹង អើលោកឮពីណាមក?

យាន៖ ឮក្នុងអង្គភាពហ្នឹងឯង ។

ដានី៖ ឮខាងគ្នាឯងនិយាយចឹង ឬក៏ធ្លាប់បានឮផ្ទាល់ពីតាម៉ុកគាត់និយាយ?

យាន៖ អត់ទេ! ខ្ញុំមិនដែលឮគាត់និយាយ ខ្ញុំមិនដែលជួបគាត់ទេ ។

បូលី៖ នៅប្រទាំងប្រទិសធំ ប្រវត្តិសាស្ត្រ២ហ្នឹង ប្រវត្តិសាស្ត្រពីមុនតាមខ្ញុំ សម្ភាសន៍ខ្លះថាម៉ុក ចរចា តែប៉ុល ពតអ្នករាំងស្ទះ? ខ្លះនិយាយថាប៉ុលពតចង់ចរចា តែតាម៉ុកអ្នករាំងស្ទះ ។ ចឹង សំណេរដែលយើងសរសេរចេញទៅ អាពីរហ្នឹងទទឹងទទាំង!

យាន៖ នៃមួយរាកម្ងាំងដែរ តាប៉ុល ពតហាមណា កងទ័ពទាំងអស់ហូរឈាមគ្នាឯងទេ ។ តាប៉ុល ពត បញ្ជាដាច់ខាត អត់ឲ្យវាយគ្នាឯងទេ ។ ចឹងហើយបានពួកខ្ញុំ តា០៥ តាយន តា៩២០ តាសាន តាអីដែលមកចុះចូល មិនតាម៉ុកថាបាតដៃឯងអត់មានប្រលាក់ឈាមទេ ។ ពួកឯង រាល់គ្នាមកចូល តា០៥ថាតាម៉ុកសម្លាប់គាត់ រួចទៅសម្លាប់មែន មិនដាក់នៅក្នុងទ្រុងដែក ។ អូនឯងវិភាគមើលប៉ុណ្ណឹងដឹងហើយ ។

បូលី៖ ហេតុអ្វីបានជាប៉ុល ពត បញ្ជាឲ្យសម្លាប់តា០៥ សម្លាប់តាសុន សេន?

យាន៖ ទេ! ខ្ញុំមិនដឹងទេអារឿងហ្នឹង អាកាលដែលសម្លាប់នោះខ្ញុំមិនដឹងទេ ។ មិនដឹងយ៉ាងម៉េច ប្រើវិធីសាស្ត្រយ៉ាងម៉េច អីយ៉ាងម៉េចខ្ញុំមិនដឹងទេសម្លាប់ ។

បូលី៖ ចុះពូដឹងថា សុន សេន ស្លាប់?

យាន៖ ហ៉េ! ដឹង១ថាគេសម្លាប់ ប៉ុនដឹងរឿងថាតាសុន សេនស្លាប់មិនដឹងថាពីណាបាញ់ មិនដឹងខាង ណា ។

បូលី៖ មិនដឹងខាងណាបាញ់ទេ?

យាន៖ មិនដឹងទេ ។

បូលី៖ ពីព្រោះបន្ទាប់ពីសុន សេនស្លាប់ហ្នឹងហើយបានតាម៉ុករៀបចំកម្លាំងមកវាយតាមហ្នឹងតា ប៉ុល ពត?

យាន៖ ហ្នឹងហើយវាការឆ្វេរជ្រៅរបស់វា គ្រាន់តែខ្ញុំដឹងថា យើងត្រូវវិភាគ បើថាតាប៉ុល ពត គាត់ថាផ្សះផ្សាកម្លាំងពួកខ្ញុំ មួយដឹងណា ហើយគេចរចាគ្នានៅប្រាសាទព្រះវិហារ ជាមួយរដ្ឋាភិបាលចឹងណា ។

បូលី៖ បាទ! អាហ្នឹងខ្ញុំដឹង ។

យាន៖ នេះមិនមែនជាគនិតរបស់តាម៉ុកទេ រូបតា០៩អីសុទ្ធតែកូនអ៊ុកអាពត ។

បូលី៖ ព្រោះអ្នកដែលចរចាផ្ទាល់ហ្នឹង គឺតាខៀវ សំផន និងតា(ស្តាប់ពុំបាន) ដែលអ្នកស្និតជាមួយតាប៉ុល ពត ។

យាន៖ បើសម្ភាសន៍ជាមួយតាប្រណាល់ដឹងហើយ មិនដឹងណាគេច្បាស់ ដែលគាត់នៅតា ទៅជួបហ្នឹងគាត់ដឹងហើយ ។

បូលី៖ ប៉ុនមាន១ក្រុមគាត់ចរចាជាមួយហ៊ុន សិនប៊ិចដែរ?

យាន៖ អាហ្នឹងនិយាយរឿងយន្តហោះនោះ ។

បូលី៖ ក្រុមតាមតាបាវ?

យាន៖ ហ្នឹងហើយ! អាហ្នឹងក៏ពួកមិនមែនឲ្យស្លាប់ទេណា តាមខ្ញុំព្រដែលកន្ទុំរុយចុះនៅអីឯណានោះ?

បូលី៖ នៅរមៀត?

យាន៖ បាទ! នៅរមៀតហ្នឹង សួរមើលមានអ្នកនៅខ្លះ ។

បូលី៖ អាហ្នឹងតាម៉ុកចរចាជាមួយខាងឆៃ ខាងសារឿនដែរ ។ ចឹងវាអាចមានការចរចាពីរតាមមើល ។ ១ចរចានៅព្រះវិហារ ១ចរចានៅខាងរមៀត ។ តាម៉ុកចរចាខាងនោះទៅ តាប៉ុល ពតចរចាខាងនេះទៅ ។

យាន៖ បាទ!

បូលី៖ ដែលប្រទះគ្នាទេពីរហ្នឹង?

អ្នកជិតខាង៖ អាហ្នឹងវាតែងតែចឹងឯង អាមួយចរចាខាង ហ៊ុន សិនប៊ិច , ហ៊ុន សិនប៊ិន មិនមារដ្ឋាភិបាលដែរខាងហ្នឹង ចង់ទៅចុលជាមួយអាមេរិក ហើយមួយទៀតចរចាជាមួយហ៊ុន សែន ខាងវៀតណាម យួន! វាប្រឆាំងគ្នាអីចឹង ហើយតាមើលនោះ ។

ដានី៖ វាចេះបើតាមយើងនិយាយឲ្យវាជាក់ស្តែងទៅខាងហ៊ុន សិនប៊ិចហើយខាង CPP គាត់ជាក្នុងរដ្ឋាភិបាលមួយ ក្នុងរាជរដ្ឋាភិបាល ។ ហើយ២ហ្នឹងកំពុងតែដណ្តើមប្រជែងគ្នា ហើយខាងខ្មែរ

ក្រហមនេះវា២ដែរ ។ ខាងតាប៉ុល ពត ទៅចរចាជាមួយខាង CPP នៅប្រាសាទព្រះវិហារ ហើយដល់ពេលខាងអើតាម៉ុកនេះ ចរចាជាមួយខាងហ៊ុន សិុនប៊ិច នៅខាងនេះវិញ ខាងអន្លង់វែងវិញ ចឹងដល់ពេលវាមានបញ្ហា២ហ្នឹងខាងប៉ុល ពតខាង តាម៉ុកក៏ឈ្លោះគ្នា ខាង CPP ខាងហ៊ុន សិុនប៊ិច ក៏ឈ្លោះគ្នាដែរ ។ ក្រោយមកមិនមានរដ្ឋប្រហារឆ្នាំ(ស្តាប់ពុំបាន) កក្កដា ហើយក្រោយមកតាម៉ុក ហើយតាប៉ុល ពតក៏ឈ្លោះគ្នាដែរ ។ អាហ្នឹងវាអាចយ៉ាងម៉េច បើតាមលោកពូ?

បូលីៈ ពេលហ្នឹងខាងនេះ ចៅហ្វាយខេត្តទីរងទី២នៅសៀមរាបនេះ ឈ្មោះហែម ប៊ុនធី ដែលពូទេពូ គាត់ជាអ្នកដឹកនាំកម្លាំង១៥នាក់ទាំងគាត់ណា ចុះយន្តហោះកន្ទុយហ្នឹងនៅរមៀត ហើយខាងតាម៉ុកនេះមាន ណុប សុជាតិ តាបាវ មានតាទីម ហើយមានប៉ុន្មាននាក់ទៀត តាផុន, ឃឹមផុន ។ តាផុន ទៅចរចាជាមួយខាងគេ ។

យានៈ បាទ! តាផុន កូនចៅទេដឹង កូនចៅតាម៉ុក ណា?

បូលីៈ បាទ! កូនចៅតាម៉ុក ។ ចឹងអាហ្នឹងវានៅក្នុងការសង្ស័យណោះឡើយ ។ ខ្ញុំសង្ស័យថា មួយខាងចរចាជាមួយហ៊ុន សិុនប៊ិច ខាងអន្លង់វែង ។

យានៈ ទេ! បើនិយាយចឹង ខ្ញុំជឿថាអីចឹង ។ រឿងដែលបែកបាក់គ្នា គឺដោយសារមួយចង់ចូលទៅខាងនេះ ហើយមួយចង់ចូលខាងនោះ ។

បូលីៈ ហើយតាសុន សេននេះ គ្រាន់ហ្នឹងចុះចូលដែរព្រោះកូនគាត់ សុន ឈុំហើយ នី កននេះចូលហើយ ។ ខាងសំពៅលូន កំរៀងភ្នំព្រឹក្សនេះណា ។ ចូលហើយ ចឹងបានជាតាប៉ុល ពតដឹងចាត់ការចូលមួយ ។

យានៈ អាហ្នឹងខ្ញុំថាដឹងពីណា ខ្ញុំឆ្ងល់ យើងអត់ដឹង ។

បូលីៈ ព្រោះបើតាមខ្ញុំសាកសួរទៅគឺថាតាប៉ុល ពតគឺពិតជាបញ្ជាឲ្យសម្លាប់ សុន សេនមែន ហើយមិនមែនគេថាទេគឺ ប៉ុល ពតខ្លួនឯងអ្នកនិយាយផ្ទាល់ ជាមួយបទសម្ភាសន៍ជាមួយនេត ថាយ័រព្រោះនេតថាយ័រ មកសម្ភាសន៍ជាមួយតាប៉ុល ពត ។ ហើយតា ប៉ុល ពតគាត់បាននិយាយថាគាត់ទទួលបានភស្តុតាងចំនួន៣ដង៩១នគាត់ធ្វើសកម្មភាពហ្នឹង គឺសំបុត្រដែលពីនាយ កន បងប្អូនរបស់ សុន សេន ។

យានៈ នាយកនគាត់ចូលទៅខាងណា?

បូលីៈ គាត់ចូលទៅរដ្ឋាភិបាល ។

ដានីៈ គាត់ចូលទៅជំនាន់អៀងសារី អ៊ីយៀងគាត់ចូលទៅបាន នី កន, សុខ ភាព អីគាត់ចូលតាមក្រោយ ។

បូលី: ចឹងប៉ុល ពត ចាប់បានសំបុត្រពីប្អូនរបស់ សុន សេន ពេលហ្នឹងហើយដែរប៉ុល ពត គិតថាសុន សេនក្បត់ ចង់ចុះចូលជាមួយរដ្ឋាភិបាល ។

ដានី: ដែលមិនបានឆ្លងកាត់គាត់ ។

បូលី: ដែលមិនបានឆ្លងកាត់គាត់ ហើយក៏បញ្ជាឲ្យគាត់សម្លាប់សុន សេន ហើយក៏ផ្ទុះសង្គ្រាមប៉ុល ពត ហើយពេលហ្នឹងបានផ្ទុះសង្គ្រាម តាម៉ុក សុំជំនួយយោធាពីញឹក ប៊ុនឆៃ ពីអូរស្មាច់មក មកជួយតាម៉ុកវាយតាប៉ុល ពត ។ វាយហើយបានចាប់ផ្ដើមចរចាតទៀត ។ ប៉ុន្តែអ្វីដែលខ្ញុំសង្ស័យគឺខ្ញុំចង់សួរថា ការចរចានៅព្រះវិហារខាងណា? ខាងតាប៉ុល ពត ឬក៏តាម៉ុក? អានេះជាសំនួររបស់ខ្ញុំ តែខ្ញុំមិនមានចម្លើយទេពូ ។

យាន: វាខាងហ្នឹង គ្រាន់តែថា ខ្ញុំមិនដឹងថារដ្ឋាភិបាលថ្នាក់ដឹកនាំ គេហៅថ្នាក់ដឹកនាំណា គេមិនចុចឈ្មោះ បើថាថនាក់ដឹកនាំមិនអាចចរចានៅប្រាសាទព្រះវិហារជាមួយរដ្ឋាភិបាល ។ ប៉ុន្តែដល់ក្រោយមកទេ តាម៉ុក តាប៉ុលពត វាយគ្នាទេបានខ្ញុំចម្លែកចិត្ត ហើយចម្លែកត្រង់ថា តាប៉ុលពតគាត់បញ្ជា ដាច់ខាតមិនឲ្យបង្ហូរឈាមមិនរួមអាវុធគ្នា ឃើញទេពូកខ្ញុំទម្លាក់អាវុធ បើអាវុធវិញខាងកម្លាំងប៉ុល ពតវាច្រើនជាង ព្រោះអីតាម៉ុកគាត់សេដ្ឋកិច្ចទេ បាទ!ចឹងក៏គាត់កម្លាំងគាត់នៅ១ក្ដាប់តូចទេដែលនៅការពារគាត់ ។

បូលី: មិនមែនកម្លាំងតាម៉ុកច្រើនទេ?

យាន: អត់ទេ!

បូលី: ចុះកងពល៩៨០របស់គាត់?

យាន: បាទ! អាហ្នឹងតែប៉ុណ្ណឹងឯង ។ បើ៩២០ក៏នៅ ប៉ុល ពត ។

បូលី: នៅខាងណាត្រពាំងប្រាសាទ?

យាន: បាទ! ៩២០ នៅអន្លង់វែងមែន ឃើញទេតាសាន តាម៉ុកចាប់ទេ ។

បូលី: ចុះតាកែ ពក ៤១៧ ខាងណា ខាងប៉ុល ពត ឬខាងតាម៉ុក កែ ពកណា?

ដានី: ជុំជាតិហ្នឹង?

យាន: គាត់មកហ្នឹងហើយ មកនេះឯង ខាងតាប៉ុល ពតនេះឯង ។

បូលី: ចឹងកម្លាំងប៉ុល ពតច្រើនវិញ?

យាន: ច្រើនជាង ។

បូលី: បើតាមខ្ញុំស្ដាប់សម្ភាសន៍នៅខាងអន្លង់វែងគេថាកម្លាំងតាម៉ុក ច្រើនជាងពីព្រោះកម្លាំងតាប៉ុលពតច្រើនជាងមែន ពីព្រោះកម្លាំងភាគច្រើនចូលទៅធ្វើការនៅខាងក្នុង អាកម្លាំងគៀកៗនេះទេ ។

យានៈ នែក៎ ខ្ញុំជឿចឹងមែន ។

បូលីៈ អាចចឹងទេពូ?

យានៈ បាទ! អាចចឹងដែរ ។

បូលីៈ ចឹងហើយដែលតាម៉ុកមានប្រៀបជាងនោះ ពីព្រោះកម្លាំងច្រើនជាង ប៉ុន្តែទៅធ្វើការនៅខាងក្នុងអស់ ។

យានៈ ប៉ុន្តែគ្រាន់តែគាត់បញ្ជា មិនមានដកកម្លាំងមកវាយណា មកទប់ទល់ណាអត់ទេ គ្រាន់ថាមិនឲ្យហូរឈាមមិត្តភក្តិឯង ។

បូលីៈ កុំឲ្យហូរឈាមគ្នាឯង ។

យានៈ គ្នាឯង! គាត់ថាអីចឹង ។

អ្នកជិតខាងៈ ប៉ុន្តែពូថាប៉ុល ពតរត់ចរចាជាមួយ CPP ចុះបើអ៊ី ឈាន ចូលជាមួយ CPP យ៉ាងម៉េចក៏គេចមកនេះ ។ ចំណុចប៉ុល ពតគេចមកនេះ CPP គេចពីអ៊ី ឈានមក ។ យ៉ាងម៉េច បានគាត់គេចមក?

បូលីៈ តាំងពីភ្នំឆ័ត្រ តាំងពីអីមក ។

អ្នកជិតខាងៈ ប៉ុល ពត គេចមកនេះ កាលហ្នឹងមិនទាន់អីទេ ឲ្យមកតាម៉ុក តាម៉ុកទៅបីសទាំងមិនរួចខ្លួនទៀត ។

បូលីៈ ឲ្យតាម៉ុក បញ្ចុះបញ្ចូល អ៊ី ឈាង?

អ្នកជិតខាងៈ បញ្ចុះបញ្ចូល អ៊ី ឈាង(ស្តាប់ពុំបាន) ។

បូលីៈ ហើយដែលមកវិញទេ? អញ្ជើញចុះពូ! អរគុណពូច្រើន ។

"ចប់"